01467489

**Declassified to Public**
**12 June 2020**

លេខ: D349

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 05 / 2017
ម៉ោង (Time/Heure): 10:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៧

ភាសា ៖ អង់គ្លេស និង ខ្មែរ

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

## សំណើសុំ មតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើ សំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុង្ស
Richard ROGERS
Goran SLUITER

**ការិយាល័យរដ្ឋបាល**
ឯកឧត្តម ក្រាញ់ តូនី
Knut ROSANDHAUG

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ទី ស្រីនណា
ស៊ិន ស៊ីវ៉ន
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Martine JACQUIN
Yiqiang LIU
Lyma NGUYEN
Nushin SARKARATI

## I. មតិយោបល់បឋម

១. យើងបានសម្រេចចេញសំណើសុំមតិយោបល់នេះ ដោយសារថា យើងមានសេចក្ដីព្រួយបារម្ភយ៉ាងខ្លាំងអំពីការចាត់ចែងថវិកានាពេលបច្ចុប្បន្ននេះសម្រាប់ អ.វ.ត.ក ទាំងភាគីជាតិ ទាំងភាគីអន្តរជាតិ ហើយយើងយល់ឃើញថា ស្ថានភាពបច្ចុប្បន្ននេះ និងចក្ខុវិស័យទៅមុខទៀតសម្រាប់ពេលឥឡូវនេះ មិនស្របតាមគោលការណ៍គ្រឹះនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ នីតិរដ្ឋ និងយុត្តិសាស្ត្រតុលាការ។ នៅក្នុងកិច្ចស៊ើបសួរសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ យើងបានឈានដល់ដំណាក់កាលមួយដែលយើងជឿថា តាមពាក្យសច្ចាប្រណិធានរបស់យើងពេលចូលកាន់តំណែង យើងមានភារកិច្ចត្រូវពិចារណាលើជម្រើសទាំងអស់ និងជម្រើសណាក៏ដោយដើម្បីធានាថា ការវិវត្តទៅមុខនៅក្នុងកិច្ចស៊ើបសួរនៅចំពោះមុខតុលាការនេះ ត្រូវគោរពតាមគោលការណ៍គ្រឹះទាំងនេះ ហើយប្រសិនបើមានការបង្ហាញថាការគោរពបែបនេះមិនអាចធ្វើបានទេ ត្រូវធានាថា កិច្ចស៊ើបសួរទាំងអស់ត្រូវបញ្ចប់ក្នុងរយៈពេលមួយសមស្របដោយគ្មានដីកាដំណោះស្រាយ ដោយសារមូលហេតុតែមួយគត់ គឺមិនមានការគាំទ្រថវិកាគ្រប់គ្រាន់ពីអង្គការសហប្រជាជាតិ (“អ.ស.ប”) ប្រទេសម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលកម្ពុជា។ មុននឹងយើងចាត់វិធានការបែបនេះជាដំណោះស្រាយចុងក្រោយបង្អស់នោះ យើងត្រូវតែផ្ដល់ជូនភាគីទាំងអស់ និងការិយាល័យរដ្ឋបាល នូវឱកាសបញ្ចេញមតិយោបល់លើការយល់ឃើញរបស់យើង និងជាពិសេស ដើម្បីផ្ដល់ឱកាសឱ្យការិយាល័យរដ្ឋបាល ផ្ដល់ព័ត៌មានលម្អិតជាលាយលក្ខណ៍អក្សរអំពីដំណើរការថវិកាសម្រាប់ឆ្នាំ ២០១៧ និងចក្ខុវិស័យសម្រាប់រយៈពេលហួសពីឆ្នាំ២០១៧។

២. និយាយឱ្យសាមញ្ញ បច្ចុប្បន្ននេះ តុលាការស្ថិតនៅក្នុងស្ថានភាពដូចតទៅ។ សំណើថវិកាឆ្នាំ ២០១៧ របស់តុលាការ ត្រូវបានអនុម័តដោយតួអង្គពាក់ព័ន្ធទាំងអស់។ ការអនុម័តសំណើថវិកានេះមានន័យថាការទទួលយកថា ថវិកាដែលបានស្នើសុំ គឺជាថវិកាចាំបាច់ដើម្បីឱ្យតុលាការដំណើរការបានត្រឹមត្រូវ។ ប៉ុន្តែ ក្រោយមក មិនមានការ ផ្ដល់ថវិកាតាមកម្រិតដែលបានស្នើសុំ និងបានអនុម័ត មិនថាតាមរយៈថវិកាឧបត្ថម្ភធនរបស់ អ.ស.ប ឬតាមរយៈការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្តទេ។ ឥឡូវនេះ តុលាការ នៅខ្វះប៉ុន្មានលានដុល្លារសម្រាប់ថវិកាដែលបានអនុម័ត ហើយនាពេលថ្មីៗនេះ ចៅក្រមទាំងអស់បានទទួលព័ត៌មានដោយផ្ទាល់មាត់ពីការិយាល័យរដ្ឋបាល ថា មានភាគរយខ្ពស់មិនទំនងជាថានឹងមានថវិកាថែមទៀតសម្រា

ប់ ឆ្នាំ ២០១៧ ដើម្បីបំពេញតាមថវិកាដែលបានអនុម័ត ឬក៏ថាកម្រិតថវិកានឹងកើនឡើងបន្ទាប់ពីឆ្នាំ ២០១៧ នោះដែរ។ នេះគឺជា ឧទាហរណ៍មួយនៃគោលការណ៍ ដែលហាមឃាត់ភាគីណាមួយមិនឱ្យខ្លួនឯងប្រព្រឹត្តផ្ទុយពីការប្រព្រឹត្តិពីមុនរបស់ខ្លួនឯង ឬការប្រព្រឹត្តិមិនស៊ីសង្វាក់គ្នា ដែលត្រូវចាត់ទុកថាជាឧទាហរណ៍មួយនៃការរំលោភបំពានលក្ខខណ្ឌតម្រូវការ ប្រព្រឹត្តដោយសុទ្ធចិត្ត និងត្រូវបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ[1] ។ វាការពិត អ.វ.ត.ក ខ្លួនឯងមិនមែនជាភាគីនៅក្នុងទំនាក់ទំនងរវាង អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសម្ចាស់ជំនួយនោះទ ក៏ប៉ុន្តែ អ.វ.ត.ក ពាក់ព័ន្ធនឹងការវាយតម្លៃអំពីផលប៉ះពាល់នៃការប្រព្រឹត្តិបែបនេះមកលើសិទ្ធិនីតិវិធីរបស់ភាគីទាំងអស់នៅក្នុងកិច្ចដំណើរការនីតិវិធី និងឯករាជ្យភាពរបស់ចៅក្រមទេ។

៣. យើងដឹងយ៉ាងច្បាស់ថា ហេតុការណ៍ភូមិសាស្ត្រនយោបាយជាទូទៅនាពេលថ្មីៗនេះធ្វើឱ្យមានបន្ទុកធ្ងន់មកលើសមត្ថភាពហិរញ្ញវត្ថុរបស់ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសម្ចាស់ជំនួយ។ ប៉ុន្តែ នៅក្នុងខ្លឹមសារកថាខណ្ឌទី ២ និង ទី ៣ នៃបុព្វកថានៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ("កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា") ភាគីកិច្ចព្រមព្រៀងបានបញ្ជាក់ថា "*មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ*" ហើយ "*រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជា ប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម*"។ ការប្រព្រឹត្តិរបស់ភាគីកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ត្រូវតែ

---

[1]សូមមើល *គោលការណ៍ហាមឃាត់ភាគីណាមួយមិនឱ្យខ្លួនឯងប្រព្រឹត្តផ្ទុយពីការប្រព្រឹត្តិពីមុនរបស់ខ្លួនឯង* ( *Venire contra factum proprium*) នៅក្នុងឯកសាររបស់ Aaron X. Fellmeth និង Maurice Horwitz *មគ្គុទេសក៍អំពីភាសាឡាតាំងនៅក្នុងច្បាប់អន្តរជាតិ* Oxford Reference សំណៅតាមអ៊ីនធឺណែត ឆ្នាំ ២០១១ និងការលើកយោងនានានៅក្នុងបរិបទនៃសំណងតាមមជ្ឈត្តកម្ម នៅគេហទំព័រ៖ https://www.trans-lex.org/907000/_/prohibition-of-inconsistent-behavior/ ។

01467492



បន្ទុះបញ្ចាំងពីភាពប្រាកដប្រជានៃការប្ដេជ្ញាចិត្ត។ របៀបដែលភាគីបំពេញតាមកិច្ចសន្យានេះ ម្យ៉ាង គឺជាបុព្វសិទ្ធិរបស់ខ្លួន ប៉ុន្តែ ម្យ៉ាងទៀត គឺជាការទទួលខុសត្រូវរបស់ខ្លួនផងដែរ[2]។

៤. ក្នុងនាមជាចៅក្រម យើងមានសេចក្ដីព្រួយបារម្ភជាចម្បងអំពីយុត្តិធម៌ និងសច្ចៈភាព។ ជាធម្មតា យើងទទួលស្គាល់ថា ប្រសិទ្ធផលផ្នែកកិច្ចដំណើរការនីតិវិធីគឺមានសារៈសំខាន់ ហើយយើងខិតខំប្រឹងប្រែងគ្រប់យ៉ាងដើម្បីគោរពតាមតម្រូវការនីតិវិធីនេះ ប៉ុន្តែ ប្រសិទ្ធផលផ្នែកកិច្ចដំណើរការនីតិវិធី គឺជាសេចក្ដីព្រួយបារម្ភលំដាប់ទី ២ បើប្រៀបធៀបជាមួយនឹងសេចក្ដីព្រួយបារម្ភអំពីយុត្តិធម៌ និងសច្ចៈភាព ហើយផលលំបាកដោយសារការប៉ះទង្គិចគ្នារវាងសេចក្ដីព្រួយបារម្ភទាំងពីរនេះប្រាកដជាកើតមានឡើង។ និមិត្តសញ្ញានៃការិយាល័យរបស់យើង គឺជាជញ្ជីងយុត្តិធម៌ដែលកាន់ដោយរូបសំណាកទេវតាយុត្តិធម៌/ស្ត្រីយុត្តិធម៌ (Justitia) ដែលត្រូវថ្លឹងឲ្យស្មើគ្នារវាងទឡ្ហីករណ៍ដែលគាំទ្រ និងប្រឆាំងភាគីណាមួយ។ Justitia មិនថ្លឹងសេរីភាពរបស់ជនណាម្នាក់ ជាមួយនឹងធនធានទ្រព្យសម្បត្តិដែលមាននោះឡើយ។ យើងក៏មិនត្រូវធ្វើដូច្នេះដែរ។

## II. ប្រវត្តិនីតិវិធី

៥. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ យើងបានលើកលែងការចោទប្រកាន់លើ អ៊ឹម ចែម នៅក្នុងសំណុំរឿង ០០៤/១ ដោយសារមិនមានយុត្តាធិការបុគ្គលគ្រប់គ្រាន់[3]។ កិច្ចស៊ើបសួរសំណុំរឿង ០០៣ បានបិទបញ្ចប់នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ហើយកិច្ចស៊ើបសួរសំណុំរឿង ០០៤/២ បានបិទបញ្ចប់នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧[4]។ ភាគីនៅក្នុងសំណុំរឿង

---

[2]គ្រាន់តែជាការបង្ហាញជាឧទាហរណ៍តែប៉ុណ្ណោះ យើងអង្កេតឃើញថា ចំណាយលើយន្តហោះវាយប្រហារទំនើប F-35 Joint Strike Fighter មួយគ្រឿង នឹងអាចផ្ដល់ថវិកាដល់ អ.វ.ត.ក ទាំងមូលសម្រាប់រយៈពេលប៉ុន្មានឆ្នាំ។ *សូមមើល* សំណើថវិកាការពារជាតិឆ្នាំសារពើពន្ធ ឆ្នាំ ២០១៦ តួលេខ ៥-២ ចំណាយលើយន្តហោះប្រភេទនេះមួយគ្រឿងមានចំនួនជាង ១៩២ លានដុល្លារ។ យន្តហោះគ្មានមនុស្ស MQ-9 Reaper មួយគ្រឿងមានតម្លៃជាង ២៧ លានដុល្លារ ច្រើនជាងថវិកាភាគីអន្តរជាតិដែលបានស្នើសុំសម្រាប់ ឆ្នាំ ២០១៧។ សូមមើល dcmo.defense.gov/Portals/47/Documents/.../FY2016_Performance_Budget.pdf។

[3]សំណុំរឿង ០០៤/១ ឯកសារ D308 *ដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច)* ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧។

[4]សំណុំរឿង ០០៤ ឯកសារ D334 *សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។ សំណុំរឿង ០០៣ ឯកសារ D225 *សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង មាស មុត* ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧។

01467493



បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរថ្មី សំណើសុំមោឃភាព និងបណ្តឹងឧទ្ធរណ៍មួយចំនួន ដោយខ្លះកំពុង រង់ចាំសេចក្តីសម្រេចនៅចំពោះមុខ ស.ច.ស និងអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ហើយដីកាសម្រេចលើសំណើមួយចំនួនក្នុងចំណោមសំណើទាំងនោះ អាចនាំឱ្យមានបណ្តឹងឧទ្ធរណ៍ថែមទៀត)[5] ។ កិច្ចស៊ើបសួរសំណុំរឿង ០០៤/២ បានបិទបញ្ចប់ម្តងទៀតបន្ទាប់ពីបានបំពេញកិច្ចស៊ើបសួរមួយចំនួន[6]។ បច្ចុប្បន្ន នេះ សំណុំរឿង ០០៤ ជិតដល់ដំណាក់កាលចុងក្រោយនៃកិច្ចស៊ើបសួរហើយ។ កន្លងមក ពេលវេលាជាមធ្យមដែល អ.ប.ជ ត្រូវការដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍/សំណើសុំមោឃភាព ជាធម្មតាគឺមានរយៈពេលប្រាំមួយខែ តាមរបាយការណ៍ប្រចាំត្រីមាសស្តីពីការបញ្ចប់ការងាររបស់តុលាការ[7]។

---

[5]នៅមានសំណើសុំ ញាតិសុំមោឃភាព និង សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ដែលអាចកើតមានជាហូរហែរ។ នៅក្នុងសំណុំរឿង ០០៣ មកដល់ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៧ មានញត្តិចំនួន ៦ កំពុងរង់ចាំសេចក្តីសម្រេចនៅចំពោះមុខ ស.ច.ស។ នៅក្នុងសំណុំរឿង ០០៤/២ មានពាក្យស្នើសុំមោឃភាពចំនួន ១ កំពុងរងចាំសេចក្តីសម្រេចរបស់ អ.ប.ជ។ ក្នុងសំណុំរឿង ០០៤ មានសំណើសុំចំនួន ២ កំពុងរង់ចាំសេចក្តីសម្រេចនៅចំពោះមុខ ស.ច.ស និង សំណើសុំមោឃភាពចំនួន ៣ កំពុងរង់ចាំសេចក្តីសម្រេចនៅចំពោះមុខ អ.ប.ជ។ មានបណ្តឹងឧទ្ធរណ៍ចំនួនបីនៅចំពោះមុខ អ.ប.ជ ពាក់ព័ន្ធនឹងសេចក្តីសម្រេចដូចគ្នា ពាក់ព័ន្ធសំណុំរឿងទាំងបី។

[6]សំណុំរឿង ០០៤/២ ឯកសារ D234/2 *សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧។

[7]*សូមមើលឧទាហរណ៍៖ ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ៧* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ១៨ អាចរកបានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/ECCC_Completion_Plan_Rev_7.pdf ។ *ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ៨* ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២០ អាចរកបា នពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/ECCC%20Completion%20Plan%20-%20revision% 208.pdf។ *ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ៩* ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ២១ អាចរកបានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/Completion%20Plan-Final-Rev9%20.pdf ។ *ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ១០* ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ២១ អាចរក បានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files /Completion%20Plan%20 revision %2010.pdf។ *ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ១១* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ១៨ អាចរកបានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/Completion%20Plan%20revision%2011.pdf។

## III. ពិភាក្សា

### ក. វឌ្ឍនភាពនៃការផ្តល់ថវិកាដល់ អ.វ.ត.ក

៦. ចាប់តាំងពីដំណាក់កាលដំបូងៗនៃការបង្កើត អ.វ.ត.ក មានការលើកឡើងអំពីសេចក្តីព្រួយបារម្ភអំពីនិរន្តភាពហិរញ្ញវត្ថុរបស់តុលាការនេះ។ ចាប់តាំងពីកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យដំណើរការជាផ្លូវការនៅឆ្នាំ ២០០៣ មក អ.វ.ត.ក នៅតែបន្តមានបញ្ហាប្រឈមផ្នែកថវិកា និង កង្វះថវិកា ដោយជាច្រើន ករណីនៅតែបន្ត ជាសេចក្តីព្រួយបារម្ភជាក់ស្តែងសម្រាប់ដំណើរការនាពេលអនាគតរបស់តុលាការ។

៧. នៅក្នុងលិខិតដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ ១៩៩៧ ដែលស្នើសុំជំនួយពី អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួន *"មិនមានធនធាន ឬជំនាញអនុវត្ត"* នីតិវិធីដ៏សំខាន់ចាំបាច់ដែលជាលក្ខខណ្ឌតម្រូវរបស់សាលាក្តីបានឡើយ[8]។ ហេតុនេះ រាជរដ្ឋាភិបាលកម្ពុជា បានស្វែងរកជំនួយពី អ.ស.ប ហើយការពិភាក្សាក៏ចាប់ផ្តើមធ្វើឡើងស្តីពីរបៀបរៀបចំរចនាសម្ព័ន្ធ និងប្រភពហិរញ្ញវត្ថុរបស់តុលាការ ឱ្យបានល្អបំផុត ដើម្បីធានានិរន្តភាពឱ្យបានគ្រប់គ្រាន់។

៨. នៅពេលដែលចាប់ផ្តើមរៀបចំបង្កើត អ.វ.ត.ក ភ្លាម នៅដំណាក់កាលដំបូង អគ្គលេខាធិការ អ.ស.ប បានគិតទុកជាមុនអំពីបញ្ហានានា ដែលត្រូវពឹងផ្អែកតែលើការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្តសម្រាប់ថវិការបស់តុលាការ។ នៅក្នុងរបាយការណ៍របស់គាត់ជូនសម័យប្រជុំលើកទី ៥៧ នៃមហាសន្និបាត អ.ស.ប អគ្គលេខាធិការ បានបញ្ជាក់ថា គាត់យល់ឃើញថា តុលាការមួយដែលមានលក្ខណៈបែបនេះនឹងបង្កើតជាបន្ទុកចំណាយរបស់ អ.ស.ប តាមមាត្រា ១៧ នៃធម្មនុញ្ញ អ.ស.ប[9] ហើយគួរតែទទួលបានថវិកាពីថវិកាត្រូវបង់[10] ពីព្រោះថា៖

---

[8]មហាសន្និបាត *លិខិតដូចគ្នាចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីអគ្គលេខាធិការ ផ្ញើជូនប្រធានមហាសន្និបាត និងផ្ញើជូនប្រធានក្រុមប្រឹក្សាសន្តិសុខ និងលិខិតចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧ ពីនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រី ទី ២ នៃប្រទេសកម្ពុជា ផ្ញើជូនអគ្គលេខាធិការ* លេខ A/51/930 ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៧ អាចរកបានពីគេហទំព័រ http://www.unakrt-online.org/sites/default/files/documents/June_21_1997_letters_from_PMs-2-1.pdf (ចូលមើលនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧)។

[9]មាត្រា ១៧ ចែងថា "*(១) មហាសន្និបាត ត្រូវពិចារណា និងអនុម័តថវិការបស់អង្គការសហប្រជាជាតិ។ (២) ចំណាយរបស់អង្គការត្រូវជាបន្ទុករបស់សមាជិក តាមការបែងចែងរបស់មហាសន្និបាត។ (៣) មហាសន្និបាត ត្រូវពិចារណា និង*

"យន្តការហិរញ្ញវត្ថុដែលពឹងផ្អែកលើការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្ត នឹងមិនមែនជាប្រភពថវិកាដែលមានជានិរន្តរ៍ និងធានាថាមាន ដែលចាំបាច់ដើម្បីអាចតែងតាំងចៅក្រម សហព្រះរាជអាជ្ញាអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល ហើយអាចធ្វើកិច្ចសន្យាការងារជាមួយនឹងបុគ្គលិករដ្ឋបាល និងបុគ្គលិកជំនួយការ ព្រមទាំងអាចទិញសម្ភារៈបរិក្ខារចាំបាច់បានឡើយ។ យន្តការហិរញ្ញវត្ថុនេះក៏នឹងមិនធានាថាជាមូលដ្ឋានដើម្បីបំពេញកិច្ចស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះក្តីបានដែរ"។

[...] ប្រតិបត្តិការរបស់តុលាការមួយមិនគួរទុកឱ្យពឹងផ្អែកលើការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្តដែលប្រែប្រួលពិបាកស្មាននោះទេ។ អាចនិយាយបានយ៉ាងត្រឹមត្រូវថា តុលាការ ជាគោលការណ៍រដ្ឋធម្មនុញ្ញ គួរទទួលបានថវិកាតាមរយៈចំណូលពន្ធ ឬនៅកម្រិតអន្តរជាតិ វិញ គួរទទួលបានថវិកាតាមរយៈយន្តការដូចគ្នា គឺថវិកាត្រូវបង់[11]។

៩. ទោះបីជាមានរបាយការណ៍ពីអគ្គលេខាធិការយ៉ាងណាក៏ដោយ ក៏នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៣ មហាសន្និបាត អ.ស.ប នៅតែបន្តសម្រេចថា ចំណាយរបស់ អ.វ.ត.ក ដែលជាបន្ទុករបស់ អ.ស.ប *"ត្រូវជាបន្ទុកថវិកាស្ម័គ្រចិត្តចូលរួមចំណែកពីសហគមន៍អន្តរជាតិ..."*[12]។ សេចក្តីសម្រេចនេះត្រូវបានអនុម័តប៉ុន្មានសប្តាហ៍មុនពេលការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

---

*ឯកភាពលើការចាត់ចែងថវិកា និងហិរញ្ញវត្ថុជាមួយនឹងទីភ្នាក់ងារជំនាញ ដូចបានលើកឡើងនៅមាត្រា ៥៧ ហើយត្រូវពិនិត្យថវិការដ្ឋបាលរបស់ទីភ្នាក់ងារជំនាញបែបនោះ ក្នុងគោលបំណងដើម្បីផ្តល់អនុសាសន៍ជូនទីភ្នាក់ងារដែលជាប់ពាក់ព័ន្ធទាំងនោះ ។*

[10]ថវិកាត្រូវបង់ (assessed contributions) គឺជាថវិការបស់រដ្ឋសមាជិកនីមួយៗ ដែលត្រូវបង់សម្រាប់ចំណាយរបស់អង្គការសហប្រជាជាតិ។

[11]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការជំនុំជម្រះក្តីខ្មែរក្រហម ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ លេខ A/57/769 កថាខណ្ឌ ៧៤-៧៥។

[12]កិច្ចប្រជុំពេញអង្គលើកទី ៨៥ របស់មហាសន្និបាត អ.ស.ប ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣ *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត លេខ* A/RES/57/228 B កថាខណ្ឌ ៣។



CO. INVESTIGATING J... *E.C.C.C*C.E.T.C*

i. <u>ការវិភាគកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា</u>

១០. ទាំង កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក សុទ្ធតែចែងពីបទប្បញ្ញត្តិទាក់ទងនឹងការផ្តល់ថវិកាសម្រាប់បុគ្គលិក ចៅក្រម និង សហព្រះរាជអាជ្ញាអន្តរជាតិរបស់តុលាការ។

១១. កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ចែងថា ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ "*ជាបន្ទុករបស់អង្គការសហប្រជាជាតិ*"[13]។

១២. បន្ថែមពីលើនេះទៀត មាត្រា ១៧ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ចែងថា អ.ស.ប "*ត្រូវទទួលខុសត្រូវ*"ចំពោះប្រាក់បៀវត្សរបស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ អនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងបុគ្គលិកអន្តរជាតិដទៃទៀត ចំណាយសម្រាប់ថ្លៃទឹក ភ្លើង និងសេវាផ្សេងៗ ដោយមានការព្រមព្រៀងគ្នាដោយឡែករវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងជំនួយឧបត្ថម្ភមានកំណត់ដទៃទៀតដែលអាចចាំបាច់ ដើម្បីធានាដំណើរការរលូនដល់ការស៊ើបអង្កេត ការចោទប្រកាន់ និងអង្គជំនុំជម្រះវិសាមញ្ញ។

១៣. រាជរដ្ឋាភិបាលកម្ពុជា ទទួលខុសត្រូវចំពោះប្រាក់បៀវត្សរបស់បុគ្គលិកជាតិ និងចំណាយមួយចំនួនផ្សេងទៀតដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា[14]។

១៤. អ.ស.ប មានសិទ្ធិផ្អាកជំនួយឧបត្ថម្ភធនជាហិរញ្ញវត្ថុដល់តុលាការ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា ផ្លាស់ប្តូររចនាសម្ព័ន្ធ ឬការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ ឬក៏ធ្វើយ៉ាងណាឱ្យអង្គជំនុំ

---

[13]មាត្រា ១៦ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

[14]មាត្រា ១៤ និង ១៥ ចែងថា រាជរដ្ឋាភិបាលកម្ពុជា ត្រូវផ្តល់ និងត្រូវរ៉ាប់រងចំណាយដោយខ្លួនឯងនូវអគារសម្រាប់ប្រត្តិបត្តិការរបស់តុលាការ ព្រមទាំងសម្ភារៈប្រើប្រាស់ ការជួយសម្រួល និងសេវាកម្មផ្សេងៗទៀតដែលចាំបាច់សម្រាប់ប្រតិបត្តិការរបស់តុលាការ បន្ថែមពីលើប្រាក់បៀវត្ស និងប្រាក់បំណាច់របស់ចៅក្រមកម្ពុជា និងបុគ្គលិកម្ពុជាផ្សេងទៀត។

ជម្រះដំណើរការតាមរបៀបណាមួយ ដែលមិនសមស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ[15]។

១៥. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនជាប់កាតព្វកិច្ចចំពោះ អ.ស.ប ទេ ពីព្រោះថា ដោយខុសពីកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់នេះគឺជាច្បាប់កម្ពុជា ហើយមិនមែនជាកិច្ចព្រមព្រៀងទ្វេភាគីទេ ប៉ុន្តែ ច្បាប់នេះផ្តល់ភាពច្បាស់លាស់ថែមទៀត។ មាត្រា ៤៤ ថ្មី នៃច្បាប់នេះ ចែងថា៖

> "ការចំណាយ និងប្រាក់បៀវត្សចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកខ្មែរ ចំពោះចៅក្រមជម្រះក្តី និងចៅក្រមជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ ជាបន្ទុករបស់ថវិកាជាតិខ្មែរ។
>
> ការចំណាយចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេស ចៅក្រមជម្រះក្តី សហព្រះរាជអាជ្ញា និង សហចៅក្រមស៊ើបអង្កេតបរទេស ដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ **ជាបន្ទុករបស់អង្គការសហប្រជាជាតិ**។
>
> ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀត ដូចជារដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ"។(គូសបញ្ជាក់បន្ថែម)

១៦. ស្របតាមបទប្បញ្ញត្តិខាងលើ កិច្ចព្រមព្រៀងបន្ថែមរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក៏ចែងថា អ.ស.ប មានកាតព្វកិច្ចត្រូវទទួលបន្ទុកចំណាយជាក់លាក់ទាក់ទងនឹងប្រតិបត្តិការរបស់ អ.វ.ត.ក[16]។

១៧. កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា គឺជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលត្រូវបកស្រាយឲ្យស្របតាមច្បាប់សន្ធិសញ្ញា ហើយជាគោលការណ៍ ត្រូវបកស្រាយឲ្យ

---

[15] កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២៨។

[16] *សូមមើល* កិច្ចព្រមព្រៀងបន្ថែមរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ទំព័រ ១។



CO-INVESTIGATING JUDGES * E.C.C.C * OCIJ

ស្របតាមអនុសញ្ញាស្តីពីច្បាប់សន្ធិសញ្ញាទីក្រុងវីយែន("VCLT")[17]។ វិធានជាទូទៅស្តីពីការបកស្រាយសន្ធិសញ្ញាដែលមានចែងនៅក្នុងអនុសញ្ញា VCLT តម្រូវថា សន្ធិសញ្ញាត្រូវបកស្រាយឲ្យស្របតាមអត្ថន័យដើមនៃពាក្យពេចន៍នៅក្នុងសន្ធិសញ្ញា ទៅតាមបរិបទ និងដោយគិតពីវត្ថុបំណង និងគោលបំណងនៃសន្ធិសញ្ញានោះ[18]។ ក្នុងគោលបំណងដើម្បីបកស្រាយសន្ធិសញ្ញាណាមួយ បរិបទ បន្ថែមពីលើអត្ថបទ បុព្វកថា និងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសន្ធិសញ្ញានោះ ក៏រួមមាន៖ ការព្រមព្រៀងគ្នាទាក់ទងនឹងសន្ធិសញ្ញានោះដែលបានធ្វើឡើងរវាងភាគីទាំងអស់នៅក្នុងសន្ធិសញ្ញា និង លិខិតុបករណ៍ដែលភាគីបានធ្វើឡើងទាក់ទងនឹងការសម្រេចចុងក្រោយលើសន្ធិសញ្ញា ហើយភាគីទាំងអស់ទទួលយកថាជាលិខិតុបករណ៍មួយទាក់ទងនឹងសន្ធិសញ្ញានោះ[19]។ បូករួមជាមួយនឹងបរិបទនេះ ក៏ទាមទារផងដែរឲ្យពិចារណានូវការព្រមព្រៀងគ្នាណាមួយដែលភាគីបានធ្វើឡើងនាពេលបន្ទាប់មកទៀត ឬការអនុវត្តក្រោយមកទៀតនៅក្នុងការអនុវត្តសន្ធិសញ្ញា ដែលបង្កើតបានជាការព្រមព្រៀងគ្នារវាងភាគីទាំងអស់ទាក់ទងនឹងការបកស្រាយសន្ធិសញ្ញានោះ[20]។

១៨. តាមខ្លឹមសារសាមញ្ញត្រង់នៃខចែងនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដែលបានដកស្រង់ខាងលើ នៅពេលដែលអានខ្លឹមសារនេះឲ្យដាច់ដោយឡែកពីឯកសារផ្សេងទៀតនោះ អ.ស.ប មិនអាចលើកឡើងពីទឡ្ហីករណ៍អំពីកង្វះថវិកាពីម្ចាស់ជំនួយថាជាមូលហេតុដែលខ្លួនមិនបានបំពេញតាមចំណាយរបស់ខ្លួន តាមកិច្ចព្រមព្រៀង និងច្បាប់បានឡើយ។

១៩. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក្រោយមកត្រូវបានប្រកាសឲ្យប្រើប្រាស់ ហើយ អ.ស.ប មិនដែលបានបង្ហាញការជំទាស់ ឬសេចក្តីអង្កេតលើខ្លឹមសារនៃច្បាប់នេះឡើយ។ ច្បាប់នេះចែងកាន់តែច្បាស់រវាងចំណាយដែល"*ជាបន្ទុករបស់អង្គការសហប្រជាជាតិ*" ជាមួយនឹងការទទួលជំនួយបន្ថែមសម្រាប់ការចំណាយពី"*មូលនិធិស្ម័គ្រចិត្តដទៃទៀតដូចជា រដ្ឋាភិបាលបរទេស*

---

[17]កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២។ *សូមមើលផងដែរ* របាយការណ៍របស់អគ្គលេខាធិការស្តីពីការជំនុំជម្រះក្តីខ្មែរក្រហម សម័យប្រជុំលើកទី ៥៧ នៃមហាសន្និបាត លេខ A/57/769 ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ២៥។

[18]អនុសញ្ញា VCLT មាត្រា ៣១(១)។

[19]អនុសញ្ញា VCLT មាត្រា ៣១(២)។

[20]អនុសញ្ញា VCLT មាត្រា ៣១(៣)។



ECCC * CETC

01467499



..."[21]។ តាមខ្លឹមសារសាមញ្ញត្រង់នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ភាពខុសគ្នារវាងចំណាយទាំងពីរប្រភេទនេះ បង្ហាញឲ្យឃើញថា មួយជាប្រភេទចំណាយដែលត្រូវធានាដោយ អ.ស.ប ហើយមួយទៀតពឹងផ្អែកលើជំនួយបន្ថែមដែលមិនមានការធានា។ ខ្លឹមសារនេះនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺស្របគ្នាជាមួយនឹងខ្លឹមសារសាមញ្ញត្រង់ខចែងនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដូចបានពិភាក្សានៅកថាខណ្ឌមុន។

២០. បន្ថែមពីលើនេះទៀត អាចមានទឡ្ហីករណ៍ថា ប្រសិនបើ អ.ស.ប ពិតជាមានបំណងដាក់លក្ខខណ្ឌចំពោះកាតព្វកិច្ចផ្នែកថវិការបស់ខ្លួនតាមកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា អាស្រ័យលើថវិកាស្ម័គ្រចិត្តពីម្ចាស់ជំនួយមែននោះ មានការរំពឹងដោយសមហេតុផលថា ភាគីទាំងពីរនឹងឯកភាពគ្នាចែងកាតព្វកិច្ចមានលក្ខខណ្ឌបែបនេះ យ៉ាងច្បាស់រួចទៅហើយនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែមិនមានចែងពីលក្ខខណ្ឌបែបនេះទេ។ ពិតណាស់ ខចែងមួយយ៉ាងច្បាស់អំពីការពឹងផ្អែករបស់ អ.ស.ប លើថវិកាស្ម័គ្រចិត្ត គឺមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងរបស់ អ.ស.ប ជាមួយនឹងរដ្ឋាភិបាលសេរ៉ាឡេអូន នៅក្នុងការបង្កើតតុលាការពិសេស សម្រាប់សេរ៉ាឡេអូន ("SCSL")[22]។

២១. យ៉ាងណាក៏ដោយ មានការបកស្រាយផ្សេងអំពីខចែងទាំងនេះនៅក្នុងបរិបទនៃសេចក្តីសម្រេចលេខ ៥៧/២២៨ របស់មហាសន្និបាត អ.ស.ប ដែលបានអនុម័តនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០២ ពោលគឺប៉ុន្មានសប្តាហ៍មុនពេលការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និងមួយឆ្នាំមុនពេលការប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ បុព្វកថានៃកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា រំឭកឡើងវិញយ៉ាងច្បាស់អំពីសេចក្តីសម្រេចនោះ។ សេចក្តីសម្រេចនោះមិនមានការបញ្ជាក់ណាមួយទាក់ទងនឹងយន្តការថវិកាសម្រាប់តុលាការទេ ប៉ុន្តែ សេចក្តីសម្រេចពាក់ព័ន្ធដែលបានចេញក្រោយមកទៀតមានលេខ ៥៧/២២៨ ខ អនុម័តដោយគ្មានការបោះឆ្នោតនៅថ្ងៃទី ២២

---

[21]ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤៤ ថ្មី។

[22]កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរដ្ឋាភិបាលសេរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់សេរ៉ាឡេអូន មាត្រា ៦ ចែងថា៖ "*ចំណាយរបស់តុលាការពិសេស ត្រូវជាបន្ទុកថវិកាស្ម័គ្រចិត្តពីសហគមន៍អន្តរជាតិ*"។

ខែ ឧសភា ឆ្នាំ ២០០៣[23] បានបញ្ជាក់ថា បន្ទុកចំណាយរបស់ អ.ស.ប តាមយន្តការថវិកាដែលបានស្នើសម្រាប់តុលាការ *"ត្រូវជាបន្ទុកថវិកាស្ម័គ្រចិត្តចូលរួមចំណែកពីសហគមន៍អន្តរជាតិ[...]"*[24]។ សេចក្តីសម្រេចលេខ ៥៧/២២៨ ខ មិនបានលើកយោងនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាទេ ហើយការប្រកាសសេចក្តីសម្រេចនេះទាក់ទងនឹងការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្ត ក៏មិនមានចែងនៅត្រង់ណាដែរនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ ប៉ុន្តែ សេចក្តីសម្រេចលេខ ៥៧/២២៨ ខ នៅជើងទំព័រ ១ បញ្ជាក់ថា សេចក្តីសម្រេចលេខ ៥៧/២២៨ ត្រូវដាក់លេខថ្មី គឺលេខ ៥៧/២២៨ ក។ ហេតុនេះ យើងចាត់ទុកខ្លឹមសារនៃសេចក្តីសម្រេចលេខ ៥៧/២២៨ ក និងលេខ ៥៧/២២៨ ខ បញ្ចូលគ្នាជាសេចក្តីសម្រេចលេខ ៥៧/២២៨។

២២. សេចក្តីសម្រេចលេខ ៥៧/២២៨ បង្ហាញឱ្យឃើញថាមានបរិបទពាក់ព័ន្ធនឹងមាត្រា ៣១ នៃអនុសញ្ញា VCLT សម្រាប់គោលបំណងបកស្រាយកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដោយពិនិត្យឃើញថា សេចក្តីសម្រេចនេះត្រូវបានរំឭកឡើងវិញយ៉ាងច្បាស់នៅបុព្វកថានៃកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ យើងក៏យល់ឃើញថាជាការពាក់ព័ន្ធផងដែរចំពោះការពិតដែលថា ដូចបង្ហាញខាងក្រោមនេះ[25] ការអនុវត្តរបស់ អ.ស.ប រហូតមកដល់សព្វថ្ងៃនេះ បើតាមការដឹងមិនមានការជំទាស់ពីរាជរដ្ឋាភិបាលកម្ពុជា ទេ គឺថា ទោះបីជាមានថវិកាឧបត្ថម្ភធនានាពេលថ្មីៗនេះពី អ.ស.ប ក៏ដោយក៏ អ.ស.ប បានពឹងផ្អែកជាចម្បងលើថវិកាស្ម័គ្រចិត្តដើម្បីបំពេញកាតព្វកិច្ចផ្នែកថវិការបស់ខ្លួនដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ ការអនុវត្តនេះបង្ហាញឱ្យឃើញពីការឯកភាពគ្នានាពេលបច្ចុប្បន្ននេះរវាងភាគីទាំងពីរចំពោះការយោគយល់គ្នាលើកិច្ចព្រមព្រៀង ដែលនេះគឺជាកត្តាពាក់ព័ន្ធមួយសម្រាប់បកស្រាយកិច្ច

---

[23]សេចក្តីសម្រេចណាមួយរបស់មហាសន្និបាត អ.ស.ប ដែលបានអនុម័តដោយគ្មានការបោះឆ្នោត បង្ហាញថា រដ្ឋសមាជិកបានឯកភាពគ្នាលើបញ្ហានានារួចហើយ ហេតុនេះនាំឱ្យលុបចោលតម្រូវការបោះឆ្នោតជាផ្លូវការណ៍ *សូមមើល* http://www.un.org/en/ga/about/background.shtml [ចូលពិនិត្យមើលចុងក្រោយនៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៧]។

[24]កិច្ចប្រជុំពេញអង្គលើកទី ៨៥ នៃ មហាសន្និបាត អ.ស.ប ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣ *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត* លេខ A/RES/57/228 B កថាខណ្ឌ ៣។

[25]*សូមមើល* ត្រង់ផ្នែក II(ក)(ii) នៃសំណើនេះ ចំណងជើង "បទពិសោធន៍កន្លងមកក្នុងការផ្តល់ថវិកាតាមកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា"។

ព្រមព្រៀងនេះ[26]។ ដោយពិនិត្យលើកត្តាទាំងនេះ ទើបមានទឡ្ហីករណ៍សមហេតុផលថា កិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបកស្រាយថាអនុញ្ញាតឱ្យ អ.ស.ប ពឹងផ្អែកលើថវិកាស្ម័គ្រចិត្ត ដើម្បីបំពេញកាតព្វកិច្ចផ្នែកថវិការបស់ខ្លួនសម្រាប់ អ.វ.ត.ក។

២៣. ការបកស្រាយក្នុងន័យកាន់តែទូលាយបែបនេះអនុញ្ញាតឱ្យ អ.ស.ប ដកស្រង់សេចក្ដីសម្រេច លេខ ៥៧/២២៨ ក្នុងទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគេចកុំឱ្យផ្ដល់ថវិកាផ្ទាល់ពីថវិការបស់ អ.ស.ប ក្នុងរូបភាពណាមួយ ទៅរូបភាពណាមួយទៀត។ យ៉ាងណាក៏ដោយ ក៏ការបកស្រាយក្នុងន័យកាន់តែទូលាយបែបនេះ នឹងមិនកែប្រែរូបភាពនៃកាតព្វកិច្ចរបស់ភាគីទាំងពីរនៅក្នុងកិច្ចព្រមព្រៀងបានឡើយបើតាមនីតិរដ្ឋ និងគោលការណ៍នៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដូចយើងបង្ហាញខាងក្រោមនេះ។

ii. <u>បទពិសោធន៍កន្លងមកក្នុងការផ្ដល់ថវិកាតាមកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា</u>

២៤. ទោះបីជាក្រោយពេលបានសម្រេចចុងក្រោយលើកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា យ៉ាងណាក៏ដោយ ក៏នៅតែបន្តមានសេចក្ដីព្រួយបារម្ភអំពីកង្វះថវិកា និងនិរន្តរភាពថវិកាដែរ ដោយដំបូងបានពន្យារពេលអនុវត្តកិច្ចព្រមព្រៀងនេះ[27] បន្ទាប់មកធ្វើឱ្យមានសេចក្ដីព្រួយបារម្ភពីអគ្គលេខាធិការថា អ.វ.ត.ក នឹងមិនអាចបំពេញអាណត្តិរបស់ខ្លួនបានឡើយដោយសារមានការរកឃើញថា *"ខ្វះបុគ្គលិក និងថវិកាយ៉ាងច្រើន"*[28]។ ក៏ស្ដែងឱ្យឃើញយ៉ាងច្បាស់ផងដែរថា ថវិកាដើមដែលបានប៉ាន់ស្មានសម្រាប់ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា គឺមានចំនួនមិនគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការរបស់តុលាការទេ ហើយ

---

[26]Oliver Dörr និង Kirsten Schmalenbach [Eds.] *អនុសញ្ញាស្ដីពីច្បាប់សន្ធិសញ្ញាទីក្រុងវីយែន៖ មតិយោបល់* ឆ្នាំ ២០១២ Springer-Verlag Berlin Heidelberg ទំព័រ ៥២៣ [ភាសាអង់គ្លេស]។

[27]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការស្ដីពីការជំនុំជម្រះក្ដីខ្មែរក្រហម ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៤ លេខ A/59/432 កថាខណ្ឌ ១៤(ខ)។ មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការស្ដីពីការជំនុំជម្រះក្ដីខ្មែរក្រហម ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ លេខ A/59/342Add.1 កថាខណ្ឌ ៦។

[28]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការស្ដីពីការជំនុំជម្រះក្ដីខ្មែរក្រហម ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៧ លេខ A/62/304 កថាខណ្ឌ ១។

ថវិកាក៏បានចំណាយផងដែរលើសកម្មភាពដែលមិនបានព្យាករទុកជាមុន។ កង្វះថវិកានៅក្នុងគម្រោងថវិកាដើម កាន់តែនាំឱ្យមានមន្ទិលសង្ស័យលើសមត្ថភាពរបស់តុលាការ ក្នុងការបំពេញអាណត្តិរបស់ខ្លួន[29]។

២៥. នៅក្នុងរបាយការណ៍មួយនៅឆ្នាំ ២០១២ ខណៈដែលអគ្គលេខាធិការ បានទទួលស្គាល់សមិទ្ធផលគួរឱ្យកត់សម្គាល់របស់ អ.វ.ត.ក នោះ គាត់ក៏បានបង្ហាញពីបញ្ហាប្រឈមនាពេលថ្មីៗបំផុត ជាពិសេស *"វិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរដែលអាចប៉ះពាល់ប្រតិបត្តិការនាពេលអនាគតរបស់តុលាការ"*[30]។ របាយការណ៍នេះក៏បង្ហាញពី *"កង្វះហិរញ្ញវត្ថុធ្ងន់ធ្ងរ"* ដែលភាគីអន្តរជាតិកំពុងប្រឈមមុខផងដែរ[31]។ របាយការណ៍នេះបានសង្កត់ធ្ងន់ថា លទ្ធភាពរបស់ អ.ស.ប ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់អន្តរជាតិ ដើម្បីផ្តល់ថវិកាដល់ផ្នែកមួយចំនួនរបស់ អ.វ.ត.ក គឺពឹងផ្អែក *"ទាំងស្រុងលើការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្តឱ្យបានគ្រប់គ្រាន់ពីរដ្ឋនានា"*[32]។ សេចក្តីព្រួយបារម្ភទាំងនេះបានកើតឡើងបន្ទាប់ពីមានរយៈពេលខ្វះថវិកានៅឆ្នាំ ២០១១ និងឆ្នាំ ២០១២ ដោយការបន្តកិច្ចសន្យាការងារបានធ្វើឡើងជាប្រចាំខែតែប៉ុណ្ណោះ ហើយការជ្រើសរើសបុគ្គលិកបានផ្អាក[33]។

២៦. របាយការណ៍នេះបានសង្កត់ធ្ងន់ថា ស្ថានភាពថវិកាមិនគ្រប់គ្រាន់នេះបាននាំឱ្យប្រព័ន្ធផ្សព្វផ្សាយសាធារណៈបង្វែរការចាប់អារម្មណ៍លើសមិទ្ធផលរបស់តុលាការ ទៅលើបញ្ហាស្ថិរភាពហិរញ្ញវត្ថុ និងទឹកចិត្តការងារផ្ទៃក្នុងទៅវិញ ហើយបានសង្កត់ធ្ងន់ថែមទៀតថា *"ការធ្វើឱ្យកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះស្ថិតក្នុងសភាពគ្រោះថ្នាក់ដោយសារកង្វះថវិកានឹងដើរផ្ទុយពីសារអំពី"គ្មានទិទណ្ឌភាព"* ដែល អ.ស.ប តែងតែចង់បានអស់រយៈពេលជិតពីរទសវត្សមកហើយ[34]។

---

[29]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤២។

[30]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២ *ការជំនុំជម្រះក្តីខ្មែរក្រហម* លេខ A/67/380 ទំព័រ ១ [ភាសាអង់គ្លេស]។

[31]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥៦។

[32]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៦៥។

[33]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៦២។

[34]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៧០។

២៧. ចុងក្រោយបំផុតនៅឆ្នាំ ២០១៣ សេចក្តីព្រួយបារម្ភផ្នែកហិរញ្ញវត្ថុនេះនាំឱ្យមានសំណើសុំថវិកាឧបត្ថម្ភធនលើកដំបូង ផ្ញើជូនមហាសន្និបាត អ.ស.ប[35]។ ផលប៉ះពាល់ដោយសារបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុដែលកើតឡើងម្តងទៀតនេះគឺថា ការមិនមានថវិកាគ្រប់គ្រាន់ដើម្បីចំណាយលើបុគ្គលិកជាតិ បានធ្វើឱ្យបុគ្គលិកដើរចេញពីការងារ និងធ្វើកូដកម្ម[36]។ រាជរដ្ឋាភិបាលកម្ពុជា មិនបានគោរពតាមលក្ខខណ្ឌតម្រូវដែលត្រូវចំណាយលើបុគ្គលិកជាតិ ហើយនៅពេលខ្លះ អគ្គលេខាធិការដ្ឋាន អ.ស.ប ត្រូវតែ ជំរុញឱ្យប្រទេសម្ចាស់ជំនួយដែលនៅមានសន្យាផ្តល់ថវិកាដល់ អ.ស.ប បង្វែរការសន្យាផ្តល់ជំនួយទាំងនោះទៅភាគីជាតិវិញ ដើម្បីធានាថា តុលាការមានបុគ្គលិកជាតិ[37]។

២៨. សំណើសុំថវិកាឧបត្ថម្ភធនខែ តុលា ឆ្នាំ ២០១៣ បានទទួលស្គាល់ថា តម្រូវការហិរញ្ញវត្ថុឆ្នាំ ២០១៤-២០១៥ នឹងនៅបន្តជាបញ្ហាប្រឈមយ៉ាងខ្លាំងផ្នែកហិរញ្ញវត្ថុ ហេតុនេះ បានផ្តល់ជាអនុសាសន៍ថា មហាសន្និបាត អ.ស.ប គួរអនុម័តថវិកាដើម្បីបន្ថែមលើធនធានហិរញ្ញវត្ថុរបស់ អ.វ.ត.ក ព្រមទាំងលទ្ធភាពឱ្យ អ.ស.ប អាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជា នូវកម្ចីដែលអាចសងវិញបាន[38]។ មហាសន្និបាត អ.ស.ប បាន

---

[35]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/68/532 ។ មហាសន្និបាត អ.ស.ប គណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីបញ្ហាចោទផ្នែករដ្ឋបាល និងថវិកា របាយការណ៍លើកទី ១៣ ស្តីពីសំណើកម្មវិធីថវិកាសម្រាប់រយៈពេលពីរឆ្នាំ ឆ្នាំ ២០១៤-ឆ្នាំ ២០១៥ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/68/7/Add.12។ មហាសន្និបាត អ.ស.ប កិច្ចប្រជុំពេញអង្គលើកទី ៨១ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៤ *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត* លេខ A/RES/68/247 B។ មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/69/536។ មហាសន្និបាត អ.ស.ប កិច្ចប្រជុំពេញអង្គលើកទី ៨៤ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត* លេខ A/RES/69/274 B។ មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/70/403។ មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/71/338។

[36]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/68/532 កថាខណ្ឌ ៣, ៣៦។

[37]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៤។

[38]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៦-៤៨។

អនុញ្ញាតតាមសំណើសុំថវិកាឧបត្ថម្ភធន នៅខែ មេសា ឆ្នាំ ២០១៤ ដោយផ្តល់សិទ្ធថា *"ជាវិធានការពិសេស"* ថវិកាចំនួន ១៥.៥ លានដុល្លារអាចបន្ថែមលើជំនួយស្ម័គ្រចិត្តដែលបានផ្តល់ជូនតុលាការអន្តរជាតិនេះសម្រាប់រយៈពេលពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤[39]។ ប៉ុន្តែ ថវិកាទាំងនេះមិនដែលបានដកឡើយ ពីព្រោះថា ចុងក្រោយបំផុត ថវិកាស្ម័គ្រចិត្ត បំពេញបានទាំងស្រុងតាមកាតព្វកិច្ចរបស់ភាគីអន្តរជាតិសម្រាប់ឆ្នាំ ២០១៤[40]។

២៩. នៅខែ តុលា ឆ្នាំ ២០១៤ សំណើសុំថវិកាឧបត្ថម្ភធនបន្ទាប់មកទៀតបានធ្វើឡើង ដែលនេះសង្កត់ធ្ងន់ឱ្យឃើញថែមទៀតថា ស្ថានភាពហិរញ្ញវត្ថុកាន់តែលំបាកកើនឡើង។ បញ្ហានេះបង្ហាញថា មានការរំពឹងទុកថា រាជរដ្ឋាភិបាលកម្ពុជាត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបានតែតាមការចាត់ចែងថវិការួមបញ្ចូលគ្នាតែប៉ុណ្ណោះ គឺ" *ចំណែកថវិកាពីថវិកាជាតិរបស់ខ្លួន ជាមួយនឹងថវិកាស្ម័គ្រចិត្តពីសហគមន៍ម្ចាស់ជំនួយ*"[41]។ ហេតុនេះ ដើម្បីចៀសវាងកុំឱ្យរំខានដល់ដំណើរការរបស់តុលាការ ទើប អគ្គលេខាធិការបានបន្តផ្តល់កម្ចីពីធនធានថវិកាស្ម័គ្រចិត្តរបស់ភាគីអន្តរជាតិ។ ការធ្វើរបៀបនេះកាន់តែឧស្សាហ៍កើតឡើង ហើយដាក់ *"បន្ទុកខ្លាំង និងទាញហិរញ្ញវត្ថុយ៉ាងច្រើនពីធនធានរបស់ភាគីអន្តរជាតិ"*[42]។ បន្ថែមពីលើនេះទៀត រាជរដ្ឋាភិបាលកម្ពុជា បានស្នើ អ.ស.ប លុបចោលកម្ចីទាំងនេះពីព្រោះថា *"មិនមានថវិកាគ្រប់គ្រាន់ដើម្បីឱ្យរាជរដ្ឋាភិបាល សងវិញបានឡើយ"*[43]។

---

[39]មហាសន្និបាត អ.ស.ប កិច្ចប្រជុំពេញអង្គលើកទី ៨១ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៤ *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត* លេខ A/RES/68/247 B កថាខ័ណ្ឌ ៧ ។ មហាសន្និបាត អ.ស.ប បានអនុម័តថវិកាបម្រុងចំនួន ១៥.៥ លានដុល្លារ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ធ្វើបច្ចុប្បន្នភាពចុងក្រោយនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤)៖ https://www.eccc.gov.kh/en/articles/un-general-assembly-approves-us-155-million-funding-reserve។

[40]មហាសន្និបាត អ.ស.ប របាយការណ៍របស់គណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីបញ្ហាចោទផ្នែករដ្ឋបាល និងថវិកា ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៦ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/71/550 កថាខណ្ឌ ២៥។

[41]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/69/536 កថាខណ្ឌ ៤០។

[42]ដូចដើងទំព័រខាងលើ កថាខណ្ឌ ៤៣។

[43]ដូចដើងទំព័រខាងលើ។

01467505



៣០. បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុនៅតែបន្តមាន ហើយសម្រាប់ភាគីអន្តរជាតិកាន់តែយ៉ាប់យឺនថែមទៀតនៅក្នុងអំឡុងឆ្នាំ ២០១៥។ របាយការណ៍ខែ កញ្ញា ឆ្នាំ ២០១៥ របស់អគ្គលេខាធិការបានសង្កត់ធ្ងន់ថា នៅតែ*"សំខាន់សម្រាប់សហគមន៍អន្តរជាតិ ត្រូវធានាថា អង្គជំនុំជម្រះវិសាមញ្ញមានមធ្យោបាយហិរញ្ញវត្ថុ ដែលចាំបាច់ដើម្បីធានាឲ្យមានការទទួលខុសត្រូវពេញលេញ... ចំពោះឧក្រិដ្ឋកម្មមានវិសាលភាពគួរឲ្យភ្ញាក់ផ្អើលដែលបានប្រព្រឹត្តនៅក្នុងអតីតរបបខ្មែរក្រហម"*ហើយបានសង្កត់ធ្ងន់ទៀតថា *"បរាជ័យផ្នែកហិរញ្ញវត្ថុរបស់អង្គជំនុំជម្រះនឹងក្លាយជាសោកនាដកម្មជាថ្មីម្តងទៀត នៅក្នុងការស្វះស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា"*[44]។ ហេតុនេះ ទើបមានការស្នើសុំថវិកាឧបត្ថម្ភធនថែមទៀតជាពិសេសសម្រាប់ភាគីអន្តរជាតិ[45]។

៣១. ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរៃអង្គាសថវិកាយ៉ាងខ្លាំងក្លាយ៉ាងណាក៏ដោយ ក៏ទើបតែមានសំណើសុំថវិកាឧបត្ថម្ភធនបន្ថែមចុងក្រោយបំផុតនៅខែ សីហា ឆ្នាំ ២០១៦ ទេ[46]។ ដោយនៅតែបន្តខ្វះការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្ត ទើបអគ្គលេខាធិការដ្ឋានមិនអាចរក្សាទុកថវិកាបម្រុងបានវិញទេ ហេតុនេះ គ្មានយន្តការផ្តល់ថវិកាដើម្បីដោះស្រាយបញ្ហាការងារបន្ទាន់ដែលមិនអាចព្យាករបានទេ[47]។ ថវិកាឧបត្ថម្ភធន ត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហា*"ធនធានហិរញ្ញវត្ថុដែលចាំបាច់ដើម្បីធានាប្រតិបត្តិការរបស់អង្គជំនុំជម្រះ"*[48]។ សំណើនេះបានសង្កត់ធ្ងន់ថែមទៀតថា ការខ្វះថវិកាសម្រាប់ភាគីណាមួយ*"ទំនងជាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សកម្មភាពរបស់អង្គជំនុំជម្រះទាំងមូល"* [49]។

៣២. នៅខែ តុលា ឆ្នាំ ២០១៦ គណៈកម្មាធិការប្រឹក្សាយោបល់ ស្តីពី បញ្ហាចោទផ្នែករដ្ឋបាល និងថវិកា បានចេញរបាយការណ៍មួយទាក់ទងនឹងភាពចាំបាច់នៃសំណើសុំថវិកាឧបត្ថម្ភធន ខែ សីហា នោះ ដើម្បីបំពេញចន្លោះខុសគ្នារវាងការប៉ាន់ស្មានធនធានដើម ជាមួយនឹងការសើរើ

---

[44]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/70/403 កថាខណ្ឌ ៤៦។

[45]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៧។

[46]មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/71/338 កថាខណ្ឌ ៣០។

[47]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៧។

[48]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៨។

[49]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៩។

ការប៉ាន់ស្មានធនធានឆ្នាំ ២០១៧ ដែលភាពខុសគ្នានេះបានកើតឡើង ដោយសារ *"ការពន្យារពេលវេលាដែលគ្រោងទុកសម្រាប់កិច្ចស៊ើបសួរ និងសកម្មភាពដែលពាក់ព័ន្ធ"*[50] ហើយបានបញ្ជាក់ថា ថវិកាឧបត្ថម្ភធនដែលបានស្នើនឹងអាចធានា *"កិច្ចសន្យាការងារបុគ្គលិកសម្រាប់រយៈពេលមួយសមរម្យបាន ក្នុងករណីមិនមានថវិកាបន្ថែមគ្រប់គ្រាន់"*[51]។ គណៈកម្មាធិការប្រឹក្សាយោបល់ បានកត់សម្គាល់ថា អ.វ.ត.ក បានទទួលថវិកាពេញលេញតាមរយៈការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្តចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០១៣ ហើយទោះបីជាសំណើសុំឧបត្ថម្ភធនមួយចំនួនត្រូវបានធ្វើឡើង ដើម្បីបន្ថែមធនធានហិរញ្ញវត្ថុស្ម័គ្រចិត្តយ៉ាងណាក៏ដោយ ក៏ចុងក្រោយបំផុត នៅតែមានការធានាថាមានថវិកាស្ម័គ្រចិត្ត ហើយថវិកាឧបត្ថម្ភធនទាំងនេះមិនដែលបានដកឡើយ[52]។

៣៣. បន្ថែមពីលើនេះទៀត គណៈកម្មាធិការប្រឹក្សាយោបល់ បានកត់សម្គាល់ថា សំណើសុំថវិកាឧបត្ថម្ភធនចំនួនបួនដងជាប់គ្នានោះ លែងធ្វើឱ្យការស្នើបែបនេះជាករណីពិសេសទៀតហើយ[53] ហើយបានបញ្ជាក់ឡើងវិញពីការយល់ឃើញថា *"សេចក្តីសម្រេចដកយកវិញនូវថវិកាមួយចំនួនពីភាគីអន្តរជាតិសម្រាប់ឆ្នាំ ២០១៧ នឹងបំផ្លាញការចាត់ចែងថវិកាដែលមានលក្ខណៈស្ម័គ្រចិត្ត"*[54]។ ប៉ុន្តែ ដោយពិនិត្យលើបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុរបស់ អ.វ.ត.ក គណៈកម្មាធិការប្រឹក្សាយោបល់ យល់ឃើញថា អ.ស.ប គួរផ្តល់ *"ជំនួយនៅកម្រិតសង្គតិភាពជាមួយនឹងចំនួនថវិកាពិតប្រាកដដែលអាចដកបានពីអាជ្ញាធរសមត្ថកិច្ចដែលបានសន្យា"*[55] ប៉ុន្តែ បានផ្តល់អនុសាសន៍ថា មហាសន្និបាត អ.ស.ប គួរស្នើសុំអគ្គលេខាធិការ *"ផ្តល់យុត្តិកម្មឱ្យបានពេញលេញ និងលម្អិតថែមទៀត"* ដើម្បីជាអំណះអំណាងកាន់តែប្រសើរសម្រាប់សំណើសុំថវិកាឧបត្ថម្ភធននាពេលអនាគត[56]។ នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៦ មហាសន្និបាត អ.ស.ប បាន

---

[50] មហាសន្និបាត អ.ស.ប របាយការណ៍របស់គណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីបញ្ហាចោទផ្នែករដ្ឋបាល និងថវិកា ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៦ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/71/550 កថាខណ្ឌ ២០។

[51] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២១។

[52] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៥។

[53] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៧។

[54] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៨។

[55] ដូចជើងទំព័រខាងលើ។

[56] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៧។

01467507



អនុញ្ញាតឱ្យបើកថវិកាឧបត្ថម្ភធនដល់ អ.វ.ត.ក មិនឱ្យលើសពី ១១ ដុល្លារដើម្បីបន្ថែមលើ ធនធានហិរញ្ញវត្ថុរបស់ភាគីអន្តរជាតិសម្រាប់រយៈពេលពីថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧[57]។

iii. <u>សេចក្តីអង្កេតលើការប្រើប្រាស់សូចនាករណ៍សមិទ្ធផលគន្លឹះនៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ</u>

៣៤. ការិយាល័យអភិវឌ្ឍន៍សមត្ថភាពនៅនាយកដ្ឋានកិច្ចការសង្គម និងសេដ្ឋកិច្ចរបស់ អ.ស.ប ផ្តល់ជំនួយផ្នែករដ្ឋបាល និងការគ្រប់គ្រង រួមមានការត្រួតពិនិត្យលើការគ្រប់គ្រង ការចាត់ចែងកិច្ចការរដ្ឋបាលបុគ្គលិក និងចៅក្រមអន្តរជាតិ ព្រមទាំងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ អ.វ.ត.ក ដូចជា ការដាក់ស្នើថវិកា ការសម្របសម្រួលជាមួយម្ចាស់ជំនួយ និងរបាយការណ៍ហិរញ្ញវត្ថុជាដើម[58]។ យោងតាមសេចក្តីសម្រេចមួយរបស់មហាសន្និបាត អ.ស.ប ចុះឆ្នាំ ២០១៤ អ.វ.ត.ក ត្រូវរៀបចំយុទ្ធសាស្ត្របញ្ចប់ការងារដោយមានផែនទីនាំផ្លូវច្បាស់លាស់ដែលត្រូវធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាស[59]។ ផែនការបញ្ចប់ការងារទាំងនេះ និងរបាយការណ៍កន្លងមករបស់អគ្គលេខាធិការ មានបញ្ចូលបច្ចុប្បន្នភាពពី ស.ច.ស អំពីវឌ្ឍនភាពនៃកិច្ចស៊ើបសួរនីមួយៗដែលកំពុងបន្តដំណើរការ បញ្ហាប្រឈមនៅក្នុងកិច្ចស៊ើបសួរនីមួយៗ ឬកត្តាដែលអាចពន្យារពេល ព្រមទាំងការប៉ាន់ស្មានអំពីពេលវេលា និងធនធានដែលចាំបាច់ដើម្បីបញ្ចប់ការងារនៅសេសសល់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត("ក.ស.ច.ស")[60]។

---

[57]មហាសន្និបាត អ.ស.ប សម័យប្រជុំលើកទី ៧១ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៦ *ប្រធានបទពិសេសទាក់ទងនឹងថវិកាកម្មវិធីសម្រាប់រយៈពេលពីរឆ្នាំ ឆ្នាំ ២០១៦-ឆ្នាំ ២០១៧* លេខ A/C.5/71/L.19 ផ្នែក II កថាខណ្ឌ ២, ៤។ យើងកត់សម្គាល់ដោយភ្ញាក់ផ្អើលម្យ៉ាងថា មហាសន្និបាត អ.ស.ប នៅផ្នែក III កថាខណ្ឌ ៤ បានបង្ហាញពី"សេចក្តីព្រួយបារម្ភយ៉ាងខ្លាំងអំពីស្ថានភាពហិរញ្ញវត្ថុមិនល្អដែលតុលាការពិសេសសម្រាប់សេរ៉ាឡេអូន កំពុងប្រឈមមុខ" ប៉ុន្តែបែរជាលុបភាសាស្រដៀងគ្នាវិញនៅផ្នែក II ទាក់ទងនឹង អ.វ.ត.ក។

[58]ការិយាល័យអភិវឌ្ឍន៍សមត្ថភាព នាយកដ្ឋានកិច្ចការសង្គម និងសេដ្ឋកិច្ច អង្គការសហប្រជាជាតិ៖ តុលាការកម្ពុជា https://www.un.org/development/desa/cdo/cambodia-court (ចូលពិនិត្យមើលចុងក្រោយនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៧)។

[59]មហាសន្និបាត អ.ស.ប កិច្ចប្រជុំពេញអង្គលើកទី ៨១ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៤ *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត* លេខ A/RES/68/247 B ផ្នែក ១ កថាខណ្ឌ ១០។

[60]*សូមមើលឧទាហរណ៍៖ ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ៧* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ១៦-២៧ អាចរកបានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/ECCC_Completion_Plan_Rev_7



ECCC * CO-INVESTIGATING JUDGES

កន្លងមក ព័ត៌មាននេះក៏បានប្រើប្រាស់ផងដែរនៅក្នុងសំណើសុំថវិកាឧបត្ថម្ភធនដើម្បីបញ្ជាក់ពីតម្រូវការថវិកាបន្ថែមទៀត[61]។

៣៥. ទោះបីជាប្រព័ន្ធតុលាការអន្តរជាតិកាន់តែពឹងផ្អែកលើសូចនាករណ៍សមិទ្ធផលគន្លឹះ ដើម្បីតាមដានភាពជោគជ័យ និងវឌ្ឍនភាពរបស់តុលាការយ៉ាងណាក៏ដោយ ក៏យើងយល់ឃើញថាជាការមិនសមស្របទេដែលត្រូវចងភ្ជាប់ថវិកាសម្រាប់កិច្ចដំណើរការនីតិវិធីរបស់តុលាការទៅនឹងសូចនាករណ៍សមិទ្ធផលគន្លឹះនោះ។ ភាពជោគជ័យរបស់ ក.ស.ច.ស មិនអាចវាស់វែងបានតាមរយៈការកំណត់ចំនួនបរិមាណការងារជាក់លាក់ទាំងនេះបានឡើយ ពីព្រោះថា កិច្ចដំណើរការនីតិវិធីរបស់យើងគឺអាស្រ័យលើលក្ខណ: និងភាពស្មុគស្មាញនៃសំណុំរឿង សំណើ និងបណ្ដឹងឧទ្ធរណ៍ដែលភាគីសម្រេចដាក់ ពេលវេលាដែល អ.ប.ជ ត្រូវការដើម្បីសម្រេចលើបណ្ដឹងឧទ្ធរណ៍ និងពាក្យសុំមោឃភាពនៅចំពោះមុខ អ.ប.ជ ការចេញចូលបុគ្គលិកដែលមិនអាចព្យាករបាន បន្ទាប់មកបាត់បង់អ្នកមានបទពិសោធន៍ការងារនៅក្នុងស្ថាប័ន ដែលនេះគឺជាកត្តាមួយចំនួនក្នុងចំណោមកត្តាផ្សេងទៀតដែលមិនអាចធ្វើការវាស់វែងបែបនេះបានឡើយ។ ការងាររបស់ ស.ច.ស ត្រូវកំណត់ដោយឯករាជ្យភាពរបស់តុលាការ និងគោលការណ៍ជំនុំជម្រះក្ដីដោយយុត្តិធម៌ មិនមែនដោយការវាស់វែងសមិទ្ធផលការងារពីភាគីខាងក្រៅឡើយ។

---

.pdf ។ *ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ៨* ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ១៦-២៨ អាចរកបានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/ECCC%20Completion%20Plan%20-%20revision%208.pdf។ *ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ៩* ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ១៦-៣៦ អាចរកបានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/Completion%20Plan-Final-Rev9%20.pdf។ *ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ១០* ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ១៦-៣៧ អាចរកបានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/Completion%20Plan%20revision%2010.pdf។ *ផែនការបញ្ចប់ការងារ អ.វ.ត.ក កែសម្រួលលើកទី ១១* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ១៤-២៩ អាចរកបានពីគេហទំព័រ https://www.eccc.gov.kh/sites/default/files/Completion%20Plan%20revision%2011.pdf។

[61] មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៤ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/69/536។ មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/70/403។ មហាសន្និបាត អ.ស.ប របាយការណ៍របស់អគ្គលេខាធិការ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/71/338។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C *

៣៦. តុលាការធម្មនុញ្ញសហព័ន្ធរបស់អាល្លឺម៉ង់ នៅក្នុងសេចក្តីសម្រេចដ៏សំខាន់របស់ខ្លួនចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីកិច្ចសន្យាសារភាពទោសនៅក្នុងនីតិវិធីព្រហ្មទណ្ឌរបស់អាល្លឺម៉ង់[62] បានកត់សម្គាល់រួចហើយថា *"ប្រព័ន្ធបច្ចុប្បន្ននេះក្នុងការវាយតម្លៃសមិទ្ធផលការងាររបស់តុលាការ គឺពឹងផ្អែកយ៉ាងខ្លាំងលើទិន្នភាពបរិមាណ ហេតុនេះបង្កើតឱ្យមានគ្រឿងលើកទឹកចិត្តបន្ថែមដើម្បីសម្រេចរឿងក្តីឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ទោះបីជាមានហានិភ័យអាចបាត់បង់គុណភាពជាក់ស្តែងក៏ដោយ"* ហើយបានកត់សម្គាល់ទៀតថា រដ្ឋសមាជិករបស់សហព័ន្ធអាល្លឺម៉ង់ មិនបានបំពេញការទទួលខុសត្រូវរបស់ខ្លួនឱ្យបានត្រឹមត្រូវទេ ជាការទទួលខុសត្រូវដែលកើតចេញពីការកើនឡើងនូវបរិមាណសំណុំរឿងតុលាការព្រហ្មទណ្ឌនៅពេលដែលធ្វើការបែងចែកថវិកា[63]។ ប៉ុន្តែ យើងកត់សម្គាល់ថា វិធីពឹងផ្អែកលើទិន្នភាពបរិមាណបែបនេះ ច្បាស់ជាប្រភេទវិធីដែលបង្ហាញឱ្យឃើញថាបានយកជាមូលដ្ឋានដើម្បីផ្តល់ថវិកាដល់ អ.វ.ត.ក។

៣៧. ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប("CCEJ")ក៏បានលើកឡើងផងដែរនៅចំពោះមុខក្រុមប្រឹក្សាអឺរ៉ុបអំពីសេចក្តីព្រួយបារម្ភ ទាក់ទងនឹងការសង្កត់ធ្ងន់ពេកលើសូចនាករណ៍សមិទ្ធផលគន្លឹះ។ ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប ក្រោយពីការសិក្សារបស់ខ្លួនអំពីករណីដែលប៉ះពាល់ដល់ឯករាជ្យភាពរបស់តុលាការក្នុងចំណោមរដ្ឋសមាជិកមក បានយល់ឃើញថា កង្វះថវិកា និងការកាត់បន្ថយថវិកា អាចធ្វើឱ្យប្រព័ន្ធតុលាការសង្កត់ធ្ងន់ពេកលើផលិតភាពការងារ ដែលការធ្វើរបៀបនេះ ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប បានបញ្ជាក់យ៉ាងត្រឹមត្រូវថាមិនអាចចាត់ទុកថាជារង្វាស់គុណភាពយុត្តិធម៌ដែលទទួលបានឡើយ។ ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប បានបញ្ជាក់ថា *"ទំហំការងាររបស់ចៅក្រម និងរដ្ឋអាជ្ញា ត្រូវតែអាចឱ្យការងារនោះធ្វើបានឆាប់រហ័សផង និងមានគុណភាពខ្ពស់ផង"*[64]។

---

[62] Amtliche Sammlung der Entscheidungen des Bundesverfassungsgerichts, vol 133, 168 at 172។

[63] នាពេលថ្មីៗនេះ តុលាការនេះបានលើកឡើងម្តងទៀតនូវការរិះគន់នេះនៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារលេខ 2 BvR 661/16 កថាខណ្ឌ ២១ អាចរកបាននៅគេហទំព័រwww.bundesverfassungsgericht.de។

[64] ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប *បញ្ហាប្រឈមសម្រាប់ឯករាជ្យភាព និងភាពឥតលម្អៀងរបស់តុលាការនៅរដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២៥ អាចរកបាននៅគេហទំព័រ៖ http://www.coe.int/t/DGHL/cooperation/ccje/textes/SGInf(2016)3rev%20Challenges%20for%20judicial%20independence%20and%20impartiality.asp#P19_102 (ចូលមើលចុងក្រោយនៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៧)។

៣៨. យើងក៏សូមយោងលើពាក្យពេចន៍គតិបណ្ឌិតរបស់ចៅក្រម David Hunt នៅក្នុងមតិយោបល់ប្រឆាំងរបស់គាត់ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៣ នៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំង Slobodan Milošević ដែលគាត់បានថ្លែងថា៖

> "[...] ខ្ញុំបានបញ្ជាក់នាពេលថ្មីៗនេះ [...] ថា "តាមពាក្យពេចន៍ដាច់ខាតបំផុតនៃយុទ្ធសាស្ត្របញ្ចប់ការងាររបស់សាលាក្តីយូហ្គូស្លាវី ការអនុម័តដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាសន្តិសុខ មិនគួរត្រូវបកស្រាយថាជាការលើកទឹកចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ ដើម្បីជំរុញឲ្យសាលាក្តីនេះធ្វើការជំនុំជម្រះក្តីដែលមិនមែនជាការជំនុំជម្រះក្តីដោយយុត្តិធម៌នោះទេ។ ចាំបាច់ត្រូវលើកឡើងពីការបញ្ជាក់នេះម្តងទៀតនៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ ដើម្បីប្រើប្រាស់ការបញ្ជាក់នេះដោយផ្ទាល់ចំពោះសេចក្តីសម្រេចមតិភាគច្រើនរបស់អង្គជំនុំជម្រះតុលាការកំពូល។ ជាអកុសលសេចក្តីសម្រេចនេះ ដើរតាមនិន្នាការសេចក្តីសម្រេចផ្សេងទៀតនាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលធ្វើផ្ទុយ ឬក៏មិនអើពើការបកស្រាយអង្គច្បាប់ ឬវិធាននីតិវិធីដែលអង្គជំនុំជម្រះខ្លួនឯងធ្លាប់បានពិចារណាយ៉ាងប្រយ័ត្នប្រយែងរួចហើយ។ ការធ្វើរបៀបនេះបានបំផ្លាញសិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់សាលាក្តី និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការពន្យល់ដ៏សមហេតុផលតែមួយគត់សម្រាប់សេចក្តីសម្រេចទាំងនោះ ស្តែងឲ្យឃើញថាជាចេតនា[...] ចង់សម្រេចយុទ្ធសាស្ត្របញ្ចប់ការងារឲ្យបានឆាប់។ ខ្ញុំមិនអាចយល់ស្របតាមសេចក្តីសម្រេចទាំងនោះបានឡើយ ពីព្រោះថា ខ្ញុំមិនជឿថា ប្រសិនបើខ្ញុំយល់ស្របវិញ ខ្ញុំនឹងបានបំពេញភារកិច្ចរបស់ខ្ញុំ"ដោយកិត្តិយស ដោយស្មោះត្រង់ ដោយឥតលម្អៀង និងដោយសតិសម្បជញ្ញៈទេ" ពីព្រោះថា សេចក្តីប្រកាសជាឱឡារិកដែលខ្ញុំបានធ្វើឡើងនៅពេលដែលខ្ញុំក្លាយជាចៅក្រមសាលាក្តីនេះ តម្រូវឲ្យខ្ញុំមិនយល់ស្របទេ។
>
> សហគមន៍អន្តរជាតិ បានប្រគល់ជូនសាលាក្តី នូវភារកិច្ចជំនុំជម្រះក្តីជនជាប់ចោទពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ សហគមន៍អន្តរជាតិ រំពឹងថា សាលាក្តីនឹងធ្វើការជំនុំជម្រះក្តីស្របតាមសិទ្ធិរបស់ជនជាប់ចោទ[...]។ ប្រសិនបើសាលាក្តី មិនទទួលបានពេលវេលា និងលុយគ្រប់គ្រាន់ពីសហគមន៍អន្តរជាតិដើម្បីធ្វើការជំនុំជម្រះក្តីទេ នោះសាលាក្តីមិនគួរព្យាយាមជំនុំជម្រះក្តីជនទាំងនេះ ក្នុងរបៀបមួយដែលមិនស្របតាមសិទ្ធិរបស់ជនជាប់ចោទទេ។ តាមទស្សនៈរបស់ខ្ញុំ ជាការមិនត្រឹមត្រូវទេដែលពិចារណាលើយុទ្ធសាស្ត្របញ្ចប់ការងារ ឲ្យខុសពីការបកស្រាយដែលអង្គជំនុំជម្រះតុលាការកំពូល ធ្លាប់បានទទួលយករួចហើយនោះ ប្រសិនបើការធ្វើរបៀបនេះប៉ះពាល់ដល់សិទ្ធិទាំងនោះ។
>
> គេនឹងមិនវាយតម្លៃសាលាក្តីនេះតាមរយៈចំនួនសាលក្រមផ្តន្ទាទោសដែលខ្លួនបានសម្រេច ឬ

> តាមរយៈល្បឿនដែលខ្លួនបានសម្រេចយុទ្ធសាស្ត្របញ្ចប់ការងារដែល ក្រុមប្រឹក្សាសន្តិសុខបានអនុម័តនោះទេ ប៉ុន្តែ គេនឹងវាយតម្លៃសាលាក្តីនេះតាមរយៈភាពយុត្តិធម៌នៃការជំនុំជម្រះក្តីរបស់ខ្លួន។ សេចក្តីសម្រេចមតិភាគច្រើនរបស់អង្គជំនុំជម្រះតុលាការកំពូល និងសេចក្តីសម្រេចផ្សេងទៀតដែលយុទ្ធសាស្ត្របញ្ចប់ការងារ មានអាទិភាពជាងសិទ្ធិរបស់ជនជាប់ចោទនោះ នឹងធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់សាលាក្តីនេះសាយភាយមិនល្អ"[65]។

យើងឯកភាពទាំងស្រុងតាមអារម្មណ៍បែបនេះនៅក្នុងបរិបទនេះ។ អារម្មណ៍បែបនេះមានដូចគ្នានៅ អ.វ.ត.ក ដែរនៅគ្រប់ដំណាក់កាលទាំងអស់នៅក្នុងកិច្ចដំណើរការនីតិវិធី។

៣៩. ភាគីពាក់ព័ន្ធផ្សេងៗបាននិយាយយ៉ាងច្រើនអំពី"កេរដំណែល"ដែល អ.វ.ត.ក ត្រូវបន្សល់ទុកសម្រាប់កិច្ចការរដ្ឋបាលតុលាការនៅក្នុងប្រទេសកម្ពុជា និងសម្រាប់សង្គមជាទូទៅ។ យើងសូមបញ្ជាក់ថា តាមការយល់ឃើញរបស់យើង "កេរដំណែល"ណាក៏ដោយក្នុងន័យនេះមិនអាចបង្កើតឡើងដោយសិប្បនិម្មិត មិនអាចមិនឱ្យជាប់ពាក់ព័ន្ធ និងមិនពឹងផ្អែកលើការពិតជាក់ស្តែងបានឡើយ។ កេរដំណែលដែលយើងបន្សល់ទុក គឺជាកេរដំណែលដែលយើងបន្សល់ទុកគ្រប់រូបភាព ទាំងវិជ្ជមាន ទាំងអវិជ្ជមាន។ កេរដំណែលមួយដែលយើងយល់ឃើញថាតុលាការណាក៏ដោយគួរប្រឹងប្រែងឱ្យអស់សមត្ថភាព ដើម្បីចៀសវាងសម្រាប់មនុស្សជំនាន់ក្រោយទាំងអស់ គឺកេរដំណែល ដែលភាពប្រញាប់ប្រញាល់សំខាន់ជាងដំណើរការនីតិវិធីត្រឹមត្រូវ។

៤០. ប៉ុន្តែ ការពិនិត្យមើលស្ថិតិគន្លឹះៗ និងដំណើរការវិវត្តថវិការបស់ភាគីអន្តរជាតិនៅ ក.ស.ច.ស[66] ចាប់តាំងពីការចាប់ផ្តើមអាណត្តិការងាររបស់អតីត ស.ច.ស.អន្តរជាតិ Mark Harmon មក បង្ហាញឱ្យឃើញថា ភាគីអន្តរជាតិចាប់តាំងពីឆ្នាំ ២០១២ មក បានបង្កើនល្បឿនការងារយ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាច្បាប់ និងនីតិវិធី[67] ហើយពេលថ្មីៗនេះ ត្រូវធ្វើការងារ

[65]រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Slobodan Milošević* មតិយោបល់ប្រឆាំងរបស់ចៅក្រម David Hunt អំពីភាពអាចទទួលយកភស្តុតាងជាពិសេសជាទម្រង់ចម្លើយជាលាយលក្ខណ៍អក្សរ (IT-02-54-AR73.4) ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៣ កថាខណ្ឌ ២០-២២។

[66]ឯកសារថវិកាទទួលបានពីផ្នែកថវិកា និងហិរញ្ញវត្ថុរបស់ជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រោម( UNAKRT) ហើយប្រើប្រាស់ជាមូលដ្ឋានសម្រាប់ឧបសម្ព័ន្ធ ខ។

[67]ឧបសម្ព័ន្ធ ក៖ *តារាងដីកាសម្រេច ដីកាបង្គាប់ និងសេចក្តីណែនាំចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចាប់តាំងពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២*។

ទាំងនេះដោយប្រើធនធានកាន់តែតិចជាងគម្រោងថវិកា ដើម្បីសន្សំសំចៃការចំណាយ[68]។ ការធ្វើរបៀបនេះ បានដាក់បន្ទុកមិនអាចទទួលយកបានទេមកលើបុគ្គលិកអន្តរជាតិរបស់ ក.ស.ច.ស ដែលឧស្សាហ៍ធ្វើការលើសម៉ោងការងារធម្មតា ហើយក្នុងករណីខ្លះ បុគ្គលិកត្រូវមកធ្វើការដោយស្ម័គ្រចិត្តទោះបីជាឈឺក៏ដោយ។

៤១. ចាប់តាំងពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ ចៅក្រម Harmon និងចៅក្រម Bohlander បានចេញដីកាសម្រេច ដីកាបង្គាប់ និងសេចក្តីណែនាំចំនួន ៤០៣។ ក្នុងចំណោមនោះមាន ២១០ បានចេញចាប់ពីពេលដែលចៅក្រម Bohlander ចាប់ផ្តើមការងារនៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៥។ ត្រូវតែគូសបញ្ជាក់ថា ការរៀបចំសេចក្តីព្រាងដីកាសម្រេច និងដីកាបង្គាប់ គឺជាផ្នែកការងារមួយតិចជាងផ្នែកការងារផ្សេងទៀតនៅក្នុងការងារស៊ើបសួរ។ ម៉ោងធ្វើការ និងធនធានបុគ្គលិកភាគច្រើនគឺចំណាយលើការចុះបេសកកម្មដល់ទីកន្លែង ដីកាកោះហៅដល់ផ្ទះ និងការវិភាគឯកសារដែលប្រមូលបាន។ ទំហំការងាររៀបចំសេចក្តីព្រាង និងការវិភាគ អាចត្រូវកើនឡើង[69]តែពេលដែលកិច្ចស៊ើបសួរឈានដល់ដំណាក់កាលរៀបចំដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយតែប៉ុណ្ណោះ។

៤២. ភាគីជាតិនៅ ក.ស.ច.ស ក៏ប្រឈមមុខនឹងសម្ពាធខ្លាំងផ្នែកពេលវេលា និងធនធានផងដែរនៅក្នុងស្ថានភាពតឹងតែងផ្នែកថវិកានាពេលបច្ចុប្បន្ននេះ។ នៅឆ្នាំ ២០១៦ ភាគីជាតិមានបុគ្គលិកប្រាំមួយនាក់៖ ប្រធានក្រុមការងារច្បាប់ម្នាក់ មន្ត្រីច្បាប់ពីរនាក់ មន្ត្រីរងផ្នែកច្បាប់ម្នាក់ ជំនួយការរដ្ឋបាលម្នាក់ និងប្រធានក្រុមការងារវិភាគម្នាក់ ក្រៅពីអ្នកប្រឹក្សាចំនួនពីរនាក់។ ។ អ្នកប្រឹក្សាម្នាក់ ឈប់ពីការងារនៅខែ មេសា ឆ្នាំ ២០១៧ ហើយចាប់ពីខែ កញ្ញា ឆ្នាំ ២០១៧ កិច្ចសន្យាការងារសម្រាប់ប្រធានក្រុមការងារច្បាប់ម្នាក់ ប្រធានក្រុមការងារវិភាគម្នាក់ និងមន្ត្រីរងផ្នែកច្បាប់ម្នាក់ នឹងមិនបន្តទេដោយសារការរឹតត្បិតថវិកា យោងតាមលិខិតពីការិយាល័យរដ្ឋបាលចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៧ ដែលបានបញ្ជាក់បញ្ហាខាងលើនេះជូន ស.ច.ស.ជាតិ។ ដោយបុគ្គលិកមានចំនួនមានកម្រិតបែបនេះ ទើបបុគ្គលិកម្នាក់ត្រូវចាត់តាំងឱ្យទទួលខុសត្រូវជនត្រូវចោទម្នាក់នៅក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២។ ទំហំការងារសម្រាប់ភាគីជាតិនឹងកើនឡើងផងដែរនៅ

---

[68]ឧបសម្ព័ន្ធ ខ៖ *ចំនួនបុគ្គលិកភាគីអន្តរជាតិនៅ ក.ស.ច.ស (គម្រោងថវិកា និងជាក់ស្តែង)ឆ្នាំ២០១២-ឆ្នាំ ២០១៧* ។

[69]គួរកត់សម្គាល់ថា ជាធម្មតា បញ្ហានេះក៏ដូចគ្នាផងដែរសម្រាប់មេធាវីការពារក្តី និងសហព្រះរាជអាជ្ញា។



CO-INVESTIGATING JUDGES · E.C.C.C * C.E.T.C

01467513



ពេលរៀបចំដីកាដំណោះស្រាយ។ ដោយសារមានការកាត់បន្ថយបុគ្គលិកនៅឆ្នាំនេះ និងមានភាពមិនច្បាស់លាស់ទាក់ទងនឹងថវិកាឆ្នាំខាងមុខនេះទៀត ទើបបុគ្គលិកនឹងត្រូវស្ថិតក្នុងសម្ពាធកាន់តែខ្លាំង ហេតុនេះប៉ះពាល់ដល់គុណភាពការងារ និងពន្យារពេលវេលាដែលត្រូវការដើម្បីបញ្ចប់កិច្ចស៊ើបសួរ ហេតុនេះហើយប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីតុលាការទាំងអស់។

៤៣. ហេតុនេះ និយាយឱ្យចំទៅ ចំពោះយើង ស្តែងឱ្យឃើញថាមានយុត្តិកម្មស្អួចស្តើងណាស់ដើម្បីកាត់បន្ថយថវិកាសម្រាប់ភាគីអន្តរជាតិ ដោយផ្អែកលើសមិទ្ធផលការងារ ជាពិសេសដោយពិនិត្យមើលស្ថិតិទាំងនេះ។ វិធីសាស្ត្រកាត់បន្ថយថវិកាបែបនេះក៏មិនបានក្រឡេកមើលការពិតជាក់ស្តែងដែលថា ថវិកាកាន់តែតិចមានន័យថា កិច្ចដំណើរការនីតិវិធីកាន់តែយូរ ហើយចំណាយសរុបកាន់តែមានច្រើនឡើងសម្រាប់រយៈពេលវែង។

## ខ. ស្ថានភាពថវិកាបច្ចុប្បន្ននេះកំពុងបង្កគ្រោះថ្នាក់ដល់ភាពត្រឹមត្រូវនៃការស៊ើបសួរ

៤៤. នៅក្នុងអំឡុងពេលវិបត្តិថវិកាពេលមុននេះគឺនៅឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”)របស់ អ.វ.ត.ក បានសម្រេចថា៖

> “វិបត្តិផ្នែកហិរញ្ញវត្ថុនៃ អ.វ.ត.ក ធ្វើឱ្យប៉ះពាល់ដល់ស្ថាប័នតុលាការទាំងមូល និងថា វិបត្តិនេះត្រូវតែបានដោះស្រាយឱ្យបានឆាប់បំផុត ដោយការសន្យាផ្តល់យ៉ាងមុតមាំឥតកែប្រែរបស់ប្រទេសម្ចាស់ជំនួយនូវការជួយឧបត្ថម្ភដោយស្ម័គ្រចិត្តរបស់ខ្លួន ឬដោយការកែប្រែដំណើរការផ្តល់ថវិកាដល់ អ.វ.ត.ក ទៅជាកញ្ចប់ថវិកាទៀងទាត់របស់អង្គការសហប្រជាជាតិ តាមរយៈថវិកាដែលត្រូវបានកំណត់ទុក ដើម្បីបំពេញនូវកិច្ចដំណើការនីតិវិធីប្រកបដោយប្រសិទ្ធភាព ក្នុងសំណុំរឿង ០០២ និងបញ្ហាដទៃទៀតបានត្រឹមត្រូវនៅចំពោះមុខ អ.វ.ត.ក។ ប្រសិនបើពុំមានថវិកាគ្រប់គ្រាន់ក្នុងការធានានូវការជំនុំជម្រះដែលច្បាប់បានតម្រូវនោះទេ រាល់កិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក ត្រូវតែបញ្ចប់ ហើយតុលាការត្រូវបិទទ្វារ។ ក្រៅពីករណីនេះចេញ កិច្ចដំណើរការនីតិវិធីត្រូវបន្តដំណើរការ ដោយពុំមានសេចក្តីសម្រេចណាមួយលើអង្គច្បាប់ និងអង្គហេតុត្រូវទទួលរងនូវឥទ្ធិពលដោយឥតសមស្របពីហិរញ្ញវត្ថុឡើយ”[70]។

---

[70]សំណុំរឿង ០០២ ឯកសារ E284/4/8 *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២* ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ៧៥។

៤៥. យើងជឿថា ឥឡូវនេះ វិបត្តិថវិកាបច្ចុប្បន្ននេះបានឈានដល់កម្រិតមួយដែលចាំបាច់ត្រូវឱ្យយើងពិចារណាការណែនាំរបស់ អ.ជ.ត.ក ឱ្យបានហ្មត់ចត់ ពីព្រោះថា យើងមានអារម្មណ៍ថា បញ្ហានេះមិនទទួលបានការយកចិត្តទុកដាក់ពីសហគមន៍ម្ចាស់ជំនួយទេចាប់តាំងពីមានការណែនាំបែបនោះមក។ យើងមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំងថាតើ វិធីសាស្ត្ររបស់ម្ចាស់ជំនួយក្នុងការទម្លាក់ថវិកាតាមដំណាក់កាល នឹងអាចឱ្យយើងបញ្ចប់កិច្ចស៊ើបសួរសំណុំរឿងទាំងបីដែលនៅសេសសល់ឱ្យដល់ចំណុចចេញដីកាដំណោះស្រាយដែររឬអត់ ហើយជាងនេះទៀត ថាតើដីកាដំណោះស្រាយនឹងត្រូវ អ.ប.ជ បានត្រួតពិនិត្យនៅពេលបណ្តឹងឧទ្ធរណ៍ដែររឬអត់ ហើយក្នុងករណីមានដីកាបញ្ជូនទៅជំនុំជម្រះក្តី ថាតើនឹងអាចឱ្យមានការជំនុំជម្រះក្តី និងបណ្តឹងសាទុក្ខនៅក្នុងរបៀបមួយដែលស្របតាមតម្រូវការនៃវិធានច្បាប់ដែររឬអត់។

៤៦. ក្នុងបរិបទនេះ មានប្រយោជន៍ ហើយក៏មិនល្អផងដែរក្នុងពេលជាមួយគ្នានេះដែលត្រូវធ្វើការប្រៀបធៀបជាមួយនឹងប្រព័ន្ធតុលាការជាតិផ្សេងៗដែលពឹងផ្អែកលើចំណូលពន្ធ៖ គ្រាន់តែទឡ្ហីករណ៍អំពីកង្វះថវិការដ្ឋដែលពឹងផ្អែកលើចំណូលពន្ធ ឬការយោងលើវិបត្តិថវិកា មិនអាចប៉ះពាល់ដល់ការពិតដែលថា ច្បាប់ប្រទេស អនុញ្ញាតឱ្យមាន*អត្ថិភាព*នៃកិច្ចការរដ្ឋបាលតុលាការ។ និយាយម្យ៉ាងទៀត មានន័យថា ប្រព័ន្ធតុលាការព្រហ្មទណ្ឌក្នុងប្រទេស មិនប្រឈមមុខនឹងការគំរាមកំហែងថានឹងត្រូវបាត់បង់អត្ថិភាពទេ ក្នុងពេលមានធនធានតិចតួច។ ក្នុងករណីបែបនេះ ដូចយើងបានពន្យល់ខាងលើហើយ ដោយមានឧទាហរណ៍អំពីប្រទេសអាល្លឺម៉ង់ជាដើម រដ្ឋាភិបាលនានាអាចការពារខ្លួនពង្រឹងប្រសិទ្ធភាពកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការមានស្រាប់ តាមរយៈកំណែទម្រង់ច្បាប់ ដរាបណាកំណែទម្រង់បែបនេះមិនរំលោភបំពានច្បាប់ធម្មនុញ្ញរបស់ប្រទេស និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ជាធម្មតា រដ្ឋាភិបាលមិនពិចារណាថានឹងផ្អាក ឬលុបបំបាត់តុលាការទាំងអស់នោះទេ។ ប៉ុន្តែ ក្នុងករណីតុលាការអន្តរជាតិ (អន្តរជាតិភាវូបនីយកម្ម) ដូចជា អ.វ.ត.ក ជាដើម ការកាត់បន្ថយថវិកាស្ទើរតែចៀសមិនរួចពីការគំរាមកំហែងដល់អត្ថិភាពរបស់តុលាការទេ ជាពិសេសដោយសារថាក្របខណ្ឌការងារបុគ្គលិកពឹងផ្អែកលើថវិកាតាមរយៈទីភ្នាក់ងារផ្តល់ការងារ៖ និយាយម្យ៉ាងទៀត មានន័យថា នៅពេលដែលអស់ថវិកាសម្រាប់ចៅក្រម និងបុគ្គលិកអន្តរជាតិ ពេលនោះកិច្ចសន្យាការងាររបស់ពួកគាត់ត្រូវបញ្ចប់ ហើយភាគីអន្តរជាតិនឹងត្រូវបាត់រូបរាងផងដែរ។ ករណីនេះដូចគ្នានឹងភាគីជាតិដែរ។ នៅក្នុងបរិយាកាសច្បាប់ ដូចជា អ.វ.ត.ក ជាដើមដែល

ពឹងផ្អែកលើគំរូកិច្ចសហប្រតិបត្តិការគ្នា នៅគ្រប់កម្រិតទាំងអស់នៃឋានានុក្រមរបស់តុលាការ ភាគីមួយមិនអាចដំណើរការទៅបានដោយគ្មានភាគីមួយទៀតបានឡើយ[71]។

៤៧. ជាគោលការណ៍ ភាគីការពារក្តី អាចមិនមានសិទ្ធិដាច់ខាតត្រូវទទួលបានសវនាការជំនុំជម្រះក្តី តាមច្បាប់សិទ្ធិមនុស្សទេ ហើយកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ អាចផ្អាកដំណើរការបានមុនពេលមានការជំនុំជម្រះក្តី ដោយមូលហេតុគោលនយោបាយផ្នែកច្បាប់ព្រហ្មទណ្ឌ[72] ប៉ុន្តែ សេណារីយ៉ូបច្ចុប្បន្ននេះខុសគ្នាត្រង់ថា ទាំង អ.ស.ប ទាំង រាជរដ្ឋាភិបាលកម្ពុជា ទាំងសហគមន៍ម្ចាស់ជំនួយ បច្ចុប្បន្ននេះមិនបានបង្ហើបឲ្យដឹងថា សំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ គួរឈប់បន្តដោយសារមូលហេតុគោលនយោបាយ *ផ្នែកច្បាប់* មុនពេលចេញដីកាដំណោះស្រាយ ឬនៅក្នុងដីកាដំណោះស្រាយនោះទេ។

៤៨. ហើយក៏គ្មានទឡ្ហីករណ៍លើកឡើងដែរ ដោយយោងលើសេចក្តីសម្រេចមុនៗរបស់ អ.ប.ជ និងផលប៉ះពាល់ដែលអាចមានមកលើលទ្ធផលនៃបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ៖ អង្គហេតុដែលថា ចៅក្រមជាតិនៅ អ.ប.ជ បានបញ្ជាក់ដដែលៗថា តាមការយល់ឃើញរបស់ខ្លួន អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ អ៊ឹម ចែម, មាស មុត ឬ អោ អាន នោះ អាចនឹងជំហរមួយ ក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយទាក់ទងនឹងជនត្រូវចោទទាំងនោះ។ មុនដល់ពេលដាក់បណ្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចលើ

---

[71]តាមទ្រឹស្តី អាចមានការលើកឡើងពីទឡ្ហីករណ៍ថា ចៅក្រមអន្តរជាតិទាំងអស់នៅ អ.វ.ត.ក អាចបន្តបម្រើការងារបានទោះបីជាក្រោយពេលដែលពួកគាត់លែងទទួលបានប្រាក់បៀវត្សក៏ដោយ ពីព្រោះថា ជាក់ស្តែង ពួកគាត់គឺជាចៅក្រមកម្ពុជា៖ ពួកគាត់ទទួលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរបស់ប្រទេសកម្ពុជា និងទទួលបានព្រះរាជទានការតែងតាំងដោយព្រះមហាក្សត្រ ប៉ុន្តែគ្រាន់តែទទួលប្រាក់បៀវត្សពី អ.ស.ប តែប៉ុណ្ណោះ មិនមែនជាចៅក្រម អ.ស.ប ទេ។ ប៉ុន្តែ ករណីនេះខុសពីបុគ្គលិកភាគីអន្តរជាតិរបស់ចៅក្រមអន្តរជាតិទាំងអស់ មានន័យថា មិនចំនងជាថា ចៅក្រមអន្តរជាតិ នឹងអាចបម្រើការងារបានទេប្រសិនបើគ្មានបុគ្គលិកអន្តរជាតិនោះ។ ក្នុងន័យនេះ ចុងបញ្ចប់នៃកិច្ចសន្យាការងាររបស់ អ.ស.ប សម្រាប់ចៅក្រមអន្តរជាតិ ក៏មានន័យថាយ៉ាងហោចណាស់ជាចុងបញ្ចប់នៃភាគីអន្តរជាតិផ្នែកតុលាការផងដែរ។

[72] Ben Emmerson, Andrew Ashworth, Alison Macdonald [Eds.] (ឆ្នាំ ២០០៧) *សិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌ បោះពុម្ពលើកទី ២ ទីក្រុងឡុងដ៍៖* Sweet & Maxwell ទំព័រ ៤៩២ [ភាសាអង់គ្លេស]។ Jeremy McBride *សិទ្ធិមនុស្ស និងនីតិវិធីព្រហ្មទណ្ឌ៖ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប*(ក្រុមប្រឹក្សាបោះពុម្ពផ្សាយអឺរ៉ុប ឆ្នាំ ២០០៩) កថាខណ្ឌ ៦៦-៦៧។ គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប *X, Y និង Z តទល់នឹងអូស្ត្រា* (ឆ្នាំ ១៩៨០) 19 D.R. 213 ទំព័រ ២១៧-៨ [ភាសាអង់គ្លេស]។

បណ្ដឹងឧទ្ធរណ៍ ការយល់ឃើញរបស់ចៅក្រមជាតិ ជាសំឡេងភាគតិច មិនចងជាប់កាតព្វកិច្ចឡើយ។ ទោះបីជាតាមទ្រឹស្ដី វាអាចប្រែប្រួលនាពេលខាងមុខ ក៏មិនមានផលអ្វីប៉ះពាល់ដល់សេចក្ដីសម្រេចរបស់យើងទេ។ ក្របខណ្ឌស្ថាប័នទូទៅរបស់ អ.វ.ត.ក *ព្យាករ*និង*ត្រូវតែអនុញ្ញាតឱ្យមាន*ដំណើរការនីតិវិធីត្រួតពិនិត្យនៅចំពោះមុខ អ.ប.ជ ហើយចុងក្រោយបំផុតសំណុំរឿងអាចត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង និងអ.ជ.ត.ក។ ហេតុនេះ សេចក្ដីព្រួយបារម្ភរបស់យើង មិនត្រូវពាក់ព័ន្ធតែដំណាក់កាលស៊ើបសួរប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវពាក់ព័ន្ធនឹងចក្ខុវិស័យវែងឆ្ងាយជាងនេះផងដែរ។

៤៩. យើងសូមរំឭកឡើងវិញអំពីការរិះគន់របស់អគ្គលេខាធិការ នៅក្នុងរបាយការណ៍ឆ្នាំ ២០១២ របស់គាត់ទាក់ទងនឹងការផ្ដល់ថវិកាដល់ អ.វ.ត.ក ដែលគាត់បានលើកឡើងថា “*ការធ្វើឱ្យកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ ស្ថិតក្នុងសភាពគ្រោះថ្នាក់ដោយសារកង្វះថវិកា នឹងដើរផ្ទុយពីសារអំពី“គ្មាននិទណ្ឌភាព”* ដែល អ.ស.ប តែងតែចង់បានអស់រយៈពេលជិតពីរទស្សវត្សមកហើយ”[73]។ កន្លងមក មហាសន្និបាត អ.ស.ប បានបង្ហាញការប្ដេជ្ញាចិត្តអំពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយដើរតួនាទីនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យមានការទទួលខុសត្រូវ ចាប់តាំងពីពេលបង្កើតមហាសន្និបាត អ.ស.ប និងតាមរយៈសេចក្ដីសម្រេចដែលប្រកាសពីតម្រូវការពិសេសត្រូវមានកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងស្វែងរកឱ្យឃើញ ការចាប់ខ្លួន ការធ្វើបត្យាប័ន និងការដាក់ទណ្ឌកម្មជនណាដែលមានទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងបញ្ជាក់ថា រដ្ឋនានាត្រូវសហការគ្នា និងជួយស្ថាប័នតុលាការអន្តរជាតិដែលមានសមត្ថកិច្ចស៊ើបសួរ និងចោទប្រកាន់អំពីការរំលោភបំពាន[74]។ ការបន្តឱ្យ អ.វ.ត.ក ស្ថិតនៅក្នុងសភាព

---

[73]សូមមើល កថាខណ្ឌ ២៧ ខាងលើ។

[74]Beth van Schaack ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ *មហាសន្និបាត និងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិ សន្តិសុខយុត្តិធម៌* អាចរកបានពីគេហទំព័រ៖ https://www.justsecurity.org/38145/general-assembly-accountability-international-crimes/។ មហាសន្និបាត អ.ស.ប ២១៨៧ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៧៣ *គោលការណ៍នៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការស្វែងរកឱ្យឃើញ ការចាប់ខ្លួន ការធ្វើបត្យាប័ន និងការដាក់ទណ្ឌកម្មជនណាដែលមានទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* សេចក្ដីសម្រេចលេខ 3074 (XXVIII)។ មហាសន្និបាត អ.ស.ប សម័យប្រជុំលើកទី ៦០ ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០៥ *គោលការណ៍គ្រឹះ និងសេចក្ដីណែនាំអំពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ* A/Res/60/147 ឧបសម្ព័ន្ធ កថាខណ្ឌ ៤។

គ្រោះថ្នាក់មិនអាចបញ្ចប់អាណត្តិរបស់ខ្លួនបានដោយសារកង្វះថវិកា គឺដើរផ្ទុយយ៉ាងខ្លាំងខុសពីការប្ដេជ្ញាចិត្តនេះ។

៥០. ភាពផ្ទុយគ្នានេះបង្ហាញឱ្យឃើញកាន់តែច្បាស់ចំពោះប្រទេសកម្ពុជា ដែលមហាសន្និបាត អ.ស.ប បានទទួលស្គាល់ថា *"ប្រវត្តិដ៏សោកនាដកម្មរបស់ប្រទេសកម្ពុជា តម្រូវឱ្យមានវិធានការពិសេសដើម្បីធានាការពារសិទ្ធិមនុស្សរបស់ជនគ្រប់រូបនៅក្នុងប្រទេសកម្ពុជា និងមិនឱ្យត្រឡប់មកវិញនូវគោលនយោបាយ និងការអនុវត្តពីអតីតកាល[...]"* ហើយក៏បានកត់សម្គាល់យ៉ាងព្រួយបារម្ភអំពីបញ្ហានានាទាក់ទងនឹងនីតិរដ្ឋ និងដំណើរការប្រព្រឹត្តិទៅនៃប្រព័ន្ធតុលាការនៅក្នុងប្រទេសផងដែរ[75]។ អសមត្ថភាព ឬក៏គ្មានឆន្ទៈក្នុងការផ្ដល់ថវិកាសម្រាប់ការងារនៅសេសសល់ទាំងអស់របស់ អ.វ.ត.ក នឹងបំផ្លាញការកសាងសមត្ថភាព និងតម្កើងកេរដំណែលរបស់តុលាការនេះចំពោះការពង្រឹងប្រសិទ្ធភាពនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា។

៥១. បញ្ហាថវិកាបែបនេះនឹងផ្ទុយពីប្រវត្តិកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនពីមុនមក និងពេលបច្ចុប្បន្ននេះរបស់មហាសន្និបាត អ.ស.ប ក្នុងការផ្ដល់យន្តការបិទបញ្ចប់ការងារតុលាការនៅក្នុងសេណារីយ៉ូក្រោយសង្គ្រាម ដែលអគ្គលេខាធិការ បានលើកឡើងជាច្រើនឆ្នាំកន្លងមកហើយ ដូចបានឃើញខាងលើរួចហើយ។ វាក៏ហាក់ដូចជាមិនសមហេតុផលទាល់តែសោះផងដែរ សម្រាប់ អ.ស.ប ជាពិសេស ប៉ុន្តែមិនសូវធ្ងន់ធ្ងរទេសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ពីព្រោះថាកម្ពុជា ជាអ្នកអញ្ជើញ អ.ស.ប ឱ្យមកជួយដោះស្រាយរឿងអតីតកាលខ្មែរក្រហមរបស់ខ្លួន ប្រសិនបើជំរុញឱ្យមានការយល់ឃើញថា កត្តាតឹងតែងផ្នែកថវិកានៅក្នុងបរិបទនេះគួរតែអាចសំខាន់ជាងតម្រូវការនៃគោលការណ៍ជំនុំជម្រះក្តីដោយយុត្តិធម៌ ឯករាជ្យភាពរបស់តុលាការ និងនីតិរដ្ឋ ទាក់ទងនឹងសិទ្ធិរបស់ភាគីការពារក្តី ហើយថែមទាំងធ្វើឱ្យក្ដីរំពឹងទុករបស់ជនរងគ្រោះដោយសាររបបខ្មែរក្រហមទៅជាអសារបង់ឥតប្រយោជន៍។

៥២. ក្នុងនាមជាចៅក្រមស៊ើបសួរ ចក្ខុះវិស័យរបស់យើង មិនអាចផ្ដោតតែនៅត្រឹមក្របខណ្ឌ ពេលវេលាដែលចេញដីកាដំណោះស្រាយរួចហើយ ថាជាពេលវេលាចុងបញ្ចប់នៃអាណត្តិការងាររបស់យើងទេ។ ការងាររបស់ ក.ស.ច.ស នៅតែបើកចំហរ ហើយពាក់ព័ន្ធនឹងការចាប់ផ្ដើម

---

[75]មហាសន្និបាត អ.ស.ប សម័យប្រជុំលើកទី ៥៧ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៣ *សេចក្តីសម្រេចអនុម័តដោយមហាសន្និបាត៖ 52/22៖ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា* A/RE/57/225 បុព្វកថា កថាខណ្ឌ II (២)។





E.C.C.C. CO-INVESTIGATING JUDGES

01467518



កសាងសំណុំរឿងប្រសិនបើមាន គឺខុសពីការងាររបស់អង្គជំនុំជម្រះផ្សេងៗនៅ អ.វ.ត.ក ដែលទទួលពិនិត្យសំណុំរឿងណាមួយតែនៅពេលដែលមានបណ្ដឹងឧទ្ធរណ៍/បណ្ដឹងសាទុក្ខ ឬ ពាក្យសុំ (អ.ប.ជ និង អ.ជ.ត.ក) ឬប្រសិនបើមានដីកាបញ្ជូនទៅជំនុំជម្រះ (អង្គជំនុំជម្រះសាលាដំបូង)។ ប្រសិនបើគ្មានដីកាសម្រេច រួមមាន ដីកាសម្រេចលើកលែងការចោទប្រកាន់ និងដីកាសម្រេចបញ្ជូនទៅជំនុំជម្រះពី ក.ស.ច.ស ទេ នោះក៏គ្មានអង្គជំនុំជម្រះណានឹងមានការងារជាក់ស្ដែងឡើយ។ បទពិសោធន៍នៅក្នុងសំណុំរឿង ០០២/១ បានបង្ហាញឱ្យឃើញថា ការជំនុំជម្រះរឿងក្ដីមួយដែលមានទីតាំងឧក្រិដ្ឋកម្មចំនួនតិច រហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូលចេញសាលដីកាស្ថាពរ គឺមានរយៈពេលប្រហែលបីឆ្នាំ។ សំណុំរឿង ០០២/២ ស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះក្ដីនៅឡើយ ហើយឥឡូវនេះទំនងជារំពឹងថា សាលក្រមនឹងចេញនៅឆ្នាំ ២០១៨។ ពេលវេលាជាមធ្យមដែលរំពឹងទុកចាប់ពីពេលនេះទៅ សម្រាប់ សំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ គឺមិនមានភាពច្បាស់លាស់ទេ។ វាអាចយូរជាងនេះ បើពិចារណាដល់ចំនួនទីតាំងឧក្រិដ្ឋកម្មដ៏ច្រើន ទោះបីមានការកាត់បន្ថយតាមវិធានផ្ទៃក្នុងទី ៦៦ (ស្ទួន) រហូតដល់ដីកាចោទប្រកាន់ណាមួយ អាចនឹងបញ្ជូនទៅដល់អង្គជំនុំជម្រះសាលាដំបូង។ នេះដោយមិនគិតដល់ការខ្វែងយោបល់ ឬជំហរខុសគ្នាដែលអាចកើតមានឡើង ចំពោះលទ្ធផលនៃការស៊ើបអង្កេត ដោយសហចៅក្រមស៊ើបអង្កេត។ ចំពោះយើងនេះក៏មានន័យថា ចក្ខុវិស័យអំពីធនធានថវិកានាពេលអនាគតដែលមិនច្បាស់លាស់ទាល់តែសោះសម្រាប់កិច្ចដំណើរការនីតិវិធី*បន្ទាប់ពី* ចេញដីកាដំណោះស្រាយទោះជាលើកលែងការចោទប្រកាន់ក្ដី ឬបញ្ជូនទៅជំនុំជម្រះក្ដី ក៏នាំឱ្យមានបញ្ហាចោទយ៉ាងសំខាន់អំពីភាពយុត្តិធម៌សម្រាប់កិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការ ជាពិសេសទាក់ទងនឹងជំហររបស់ភាគីការពារក្ដី ដោយគិតពីអាយុរបស់ជនត្រូវចោទ និងអង្គហេតុដែលថា ជនជាប់ចោទចំនួន ២រូបនៃសំណុំរឿង ០០២ បានស្លាប់ក្នុងអំឡុងពេលសវនាការ ព្រមទាំងប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះ និងសហព្រះរាជអាជ្ញា។

៥៣. យើងនឹងបង្ហាញពីសំអាងហេតុអង្គច្បាប់របស់យើងអំពីសុវត្ថិភាពថវិកានៅក្នុងបរិបទតុលាការជាពិសេសនៅ អ.វ.ត.ក ឱ្យបានកាន់តែលម្អិតនៅក្រោមនេះ ហើយម្យ៉ាងទៀត យើងយល់ឃើញថាមិនអាចទទួលយកបានទេប្រសិនបើ៖

ក. បន្តកិច្ចស៊ើបសួរខណៈដែលមិនច្បាស់ថាតើនឹងមានថវិកាគ្រប់គ្រាន់ដែរឬអត់

ដើម្បីបញ្ចប់ការងាររបស់យើងក្នុងរបៀបមួយ ឲ្យបានត្រឹមត្រូវដល់ដំណាក់កាលចេញដីកាដំណោះស្រាយ ឬក៏ថាករណីនេះអាចទៅរួច

ខ. ចេញដីកាដំណោះស្រាយ ជាពិសេស ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើមិនច្បាស់សោះថាតើអាចមានថវិកាគ្រប់គ្រាន់ដែរឬអត់ដើម្បីឲ្យ អ.ប.ជ ត្រួតពិនិត្យផ្ទាល់លើដីកាដំណោះស្រាយនៅពេលមានបណ្តឹងឧទ្ធរណ៍ ហើយបន្តទៅមុខនេះទៀត នៅតែមានមន្ទិលយ៉ាងខ្លាំងអំពីការចូលរួមរបស់ភាគីទាំងអស់នៅក្នុងសវនាការនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង និងអ.ជ.ត.ក។

៥៤. យើងយល់ឃើញថា វាជាការមិនសមស្របតាមតម្រូវការជាមូលដ្ឋាននៃនីតិរដ្ឋប្រសិនបើទុកចោលកិច្ចស៊ើបសួរដែលមិនបានបញ្ចប់ ហើយក្នុងករណីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទុកចោលដីកាបែបនេះ ដោយសារតែការបញ្ឈប់ប្រតិបត្តិការរបស់ អ.វ.ត.ក ហើយចាក់សោទ្វារតុលាការ ដោយមូលហេតុមិនមានថវិកាថែមទៀតដើម្បីចំណាយលើបុគ្គលិក និងចំណាយផ្សេងទៀតខាងភាគីជាតិ ឬភាគីអន្តរជាតិ។ សេណារីយ៉ូនេះ ដូចយើងពន្យល់ខាងក្រោមនេះ មិនមែនជាយន្តការបិទបញ្ចប់ការងារឲ្យបានត្រឹមត្រូវតាមគោលការណ៍ជំនុំជម្រះក្តីដោយយុត្តិធម៌ ឯករាជ្យភាពរបស់តុលាការ និងនីតិរដ្ឋឡើយ ហើយក៏មិនមានចែងទុកនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដែរ។

៥៥. សេចក្តីព្រួយបារម្ភនេះកាន់តែកើនឡើងថែមទៀត ដោយសារអង្គហេតុដូចយើងនឹងបង្ហាញនៅក្នុងសំអាងហេតុនៅពេលខាងមុខនេះនៅក្នុងដីកាដំណោះស្រាយសំណុំរឿង អ៊ឹម ចែម ដែលថា នៅពេលនេះ តុលាការធម្មតារបស់កម្ពុជា មិនមានយុត្តាធិការលើសំណុំរឿងដែលបានចាប់ផ្តើមនៅក្នុងដែនសមត្ថកិច្ចរបស់ អ.វ.ត.ក ហើយនៅពេលនេះក៏មិនមានការចរចាអំពីយុទ្ធសាស្ត្រច្រកចេញប្រភេទណាមួយដែរ។ វាក៏មិនមានវិធីដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធី ដែលកំពុងមាន ទោះបីជាបញ្ចប់ក្នុងរបៀបមួយដែលមិនស្ងួវសង្គតិភាពជាមួយនឹងស្មារតីនៃកិច្ចចរចាដែលនាំឲ្យបង្កើត អ.វ.ត.ក ជាតុលាការកម្ពុជា តែមានសមាភាពគាំទ្រពីអន្តរជាតិ ក៏ដោយ។





CO. INVESTIGATING JUDGES * E.C.C.C * C.E.T.C

01467520



## គ. បទដ្ឋាន និយាម និងយុត្តិសាស្ត្រជាតិ និងអន្តរជាតិទាក់ទងការផ្តល់ថវិកា និងឯករាជ្យភាពរបស់តុលាការ

### i. សន្ធិសញ្ញា អនុសញ្ញា និងច្បាប់

៥៦. ការយល់ឃើញដែលថា កាតព្វកិច្ចរបស់ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ និងធានាថាមានថវិកាសម្រាប់ អ.វ.ត.ក ជាកាតព្វកិច្ចត្រូវតែធ្វើ ហើយមិនជាប់លក្ខខណ្ឌអាស្រ័យតាមថវិកាស្ម័គ្រចិត្តពីម្ចាស់ជំនួយនោះទេ គឺជាការយល់ឃើញស្របតាមបទដ្ឋានសិទ្ធិមនុស្ស និងយុត្តិសាស្ត្រអន្តរជាតិ ដែលគូសបញ្ជាក់ពីតម្រូវការត្រូវធានាថាមានថវិកាដើម្បីទទួលបានឯករាជ្យភាពរបស់តុលាការ និង កិច្ចការរដ្ឋបាលតុលាការប្រកបដោយប្រសិទ្ធភាព។

៥៧. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលមហាសន្និបាត អ.ស.ប បានអនុម័តនៅឆ្នាំ ១៩៦៦ ធានាថា ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបាន *"ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងដែលបង្កើតដោយច្បាប់"*[76]។

៥៨. នៅខែ ឧសភា ឆ្នាំ ១៩៨១ សមាគមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គណៈកម្មការអ្នកច្បាប់អន្តរជាតិ និងមជ្ឈមណ្ឌលដើម្បីឯករាជ្យភាពរបស់ចៅក្រម និងមេធាវី បានចងក្រងសេចក្តីព្រាងគោលការណ៍នៃឯករាជ្យភាពរបស់តុលាការ("គោលការណ៍ទីក្រុង Siracusa") ដោយសង្ឃឹមថា ពួកគេនឹងជួយអ្នករាយការណ៍ពិសេសស្តីពីការសិក្សាអំពីឯករាជ្យភាពរបស់តុលាការ ធ្វើឡើងដោយអនុគណៈកម្មការ អ.ស.ប ទទួលបន្ទុកការងារជនជាតិភាគតិច និងបង្ការការរើសអើង[77]។ កាន់តែច្បាស់ គោលការណ៍ទីក្រុង Siracusa ភ្ជាប់ស្ថិរភាពហិរញ្ញវត្ថុទៅនឹងឯករាជ្យភាពរបស់តុលាការ ដោយសង្កត់ធ្ងន់ថា *"តុលាការឯករាជ្យ គឺមិនអាចខ្វះបានឡើយ*

---

[76]មហាសន្និបាត អ.ស.ប *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ មាត្រា ១៤ http://www.ohchr.org/EN/ProfessionalInterest/Pages/CCPR.aspx (ចូលមើលនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៧)។

[77]គោលការណ៍ទីក្រុង Siracusa ថ្ងៃទី ២៥-២៩ ខែ ឧសភា ឆ្នាំ ១៩៨១ មាត្រា ១, ២៤។ http://www.cristidanilet.ro/docs/Siracusa%20Principles.pdf (ចូលមើលនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៧) (អ្នករាយការណ៍ពិសេសបានដាក់សេចក្តីព្រាងនេះជូនអនុគណៈកម្មការ ជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងរបាយការណ៍វឌ្ឍនភាពរបស់គាត់)។

*សម្រាប់ការអនុវត្ត*"សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាសាធារណៈដែលធ្វើឡើងដោយសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដូចបានធានាដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ICCPR[78] ហើយសង្កត់ធ្ងន់ថែមទៀតថា ដើម្បីធានាឯករាជ្យភាពរបស់តុលាការ *"តុលាការគួរទទួលបានមធ្យោបាយ និងធនធានដែលចាំបាច់ដើម្បីបំពេញមុខងារតុលាការរបស់ខ្លួនឱ្យបានត្រឹមត្រូវ"*[79]។ ស្រដៀងគ្នានេះដែរ គណៈមេធាវីការអន្តរជាតិ បានបង្ហាញពីបទដ្ឋានអប្បបរមានៃឯករាជ្យភាពរបស់តុលាការ ដោយបញ្ជាក់ថា ជា*"ភារកិច្ចរបស់រដ្ឋដែលត្រូវផ្តល់ធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យមានកិច្ចការរដ្ឋបាលតុលាការសមស្រប"*[80]។

៥៩. គោលការណ៍គ្រឹះ អ.ស.ប ស្តីពីឯករាជ្យភាពរបស់តុលាការ("គោលការណ៍គ្រឹះ") អនុម័តនៅឆ្នាំ ១៩៨៥ និងឯកភាពដោយសេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប[81] បានផ្តល់ភាពលម្អិតថែមទៀត ដោយបញ្ជាក់ថា *"ឯករាជ្យភាពរបស់តុលាការត្រូវធានាដោយរដ្ឋ និងត្រូវមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ប្រទេស"* ហើយជា*"ភារកិច្ចរបស់ស្ថាប័នរដ្ឋាភិបាលទាំងអស់ និងស្ថាប័នផ្សេងទៀតដើម្បីគោរព និងអនុវត្តតាមឯករាជ្យភាពរបស់តុលាការ"*[82]។ មាត្រា ២ នៃគោលការណ៍គ្រឹះ ចែងថា *"តុលាការត្រូវសម្រេចលើបញ្ហានានានៅចំពោះមុខខ្លួន ដោយឥតលម្អៀង ដោយផ្អែកលើអង្គហេតុ និងស្របតាមច្បាប់ ដោយគ្មានការរឹតត្បិត*

---

[78]គោលការណ៍ទីក្រុង Siracusa ថ្ងៃទី ២៥-២៩ ខែ ឧសភា ឆ្នាំ ១៩៨១ មាត្រា ១, ២៤ http://www.cristidanilet.ro/docs/Siracusa%20Principles.pdf (ចូលមើលនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧)។

[79]ដូចជើងទំព័រខាងលើ មាត្រា ២៤។

[80]គណៈមេធាវីអន្តរជាតិ *បទដ្ឋានអប្បបរមានៃឯករាជ្យភាពរបស់តុលាការ* ឆ្នាំ ១៩៨២ មាត្រា ១០ http://www.ibanet.org/Search/Search.aspx?query=minimum%20standards%20of%20judicial%20independence (ចូលមើលនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៧)។

[81]មហាសន្និបាត អ.ស.ប លើកទី ៧ ស្តីពីការបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តិមកលើជនល្មើស *គោលការណ៍គ្រឹះនៃឯករាជ្យភាពរបស់តុលាការ* ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៨៥ http://www.ohchr.org/EN/ProfessionalInterest/Pages/IndependenceJudiciary.aspx (ចូលមើលនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៧) អនុម័តដោយសេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ ៤០/៣២ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ និងលេខ ៤០/១៤៦ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៨៥។

[82]មហាសន្និបាត អ.ស.ប លើកទី ៧ ស្តីពីការបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តិមកលើជនល្មើស *គោលការណ៍គ្រឹះនៃឯករាជ្យភាពរបស់តុលាការ* ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៨៥ http://www.ohchr.org/EN/ProfessionalInterest/Pages/IndependenceJudiciary.aspx (ចូលមើលនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៧)។

01467522



*ឥទ្ធិពលមិនត្រឹមត្រូវ គ្រឿងលើកទឹកចិត្ត សម្ពាធ ការគំរាមកំហែង ឬអន្តរាគមន៍ ដោយផ្ទាល់ ឬដោយប្រយោលពីកន្លែងណា ឬដោយមូលហេតុណានោះទេ*” ។ គោលការណ៍គ្រឹះក៏ចែងថា ជាអាទិ៍ អាណត្តិការងារសម្រាប់ចៅក្រម ឯករាជ្យភាពរបស់ចៅក្រម និងប្រាក់បៀវត្សគ្រប់គ្រាន់ ត្រូវធានាដោយច្បាប់[83]។ ដើម្បីសម្រេចគោលបំណងនេះបាន រដ្ឋសមាជិកនីមួយៗត្រូវផ្តល់ធនធានឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យតុលាការ អាចបំពេញមុខងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ[84]។

៦០. នៅក្នុងសន្និសីទលើកទី ៦ នៅឆ្នាំ ១៩៩៥ ប្រធានតុលាការកំពូលមកពីតំបន់អាស៊ីប៉ាស៊ីហ្វិក និងផ្នែកតុលាការនៃសមាគមច្បាប់សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក (“LAWASIA”) បានជួបប្រជុំគ្នានៅទីក្រុងប៉េកាំង ហើយបានអនុម័តសេចក្តីថ្លែងការណ៍រួម ស្តីពី គោលការណ៍នៃឯករាជ្យភាពរបស់តុលាការ[85]។ ក្រោយមក សេចក្តីថ្លែងការណ៍នេះត្រូវបានកែសម្រួលនៅក្នុងសន្និសីទលើកទី៧ នៅឆ្នាំ ១៩៩៧ ហើយឥឡូវនេះ ត្រូវបានចុះហត្ថលេខាដោយប្រធានតុលាការកំពូលនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក រួមមាន អូស្ត្រាលី និងជប៉ុន ផងដែរ (ប៉ុន្តែបច្ចុប្បន្ននេះ កម្ពុជា មិនមែនជាប្រទេសហត្ថលេខីទេ)[86]។ សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងស្តីពីគោលការណ៍នៃឯករាជ្យភាពរបស់តុលាការនៃសមាគម LAWASIA បញ្ជាក់ថា “*ការរក្សាឯករាជ្យភាពរបស់តុលាការ គឺជាសំខាន់ចាំបាច់ដើម្បីសម្រេចគោលដៅរបស់តុលាការ និងបំពេញមុខងាររបស់តុលាការឱ្យបានត្រឹមត្រូវ*” ហើយឯករាជ្យភាពបែបនេះគួរត្រូវ“*ធានាដោយរដ្ឋ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់*”[87]។ សេចក្តីថ្លែងការណ៍នេះលម្អិតថែមទៀតថា ជាការ“*សំខាន់ចាំបាច់ដែលចៅក្រម ត្រូវទទួលបានធនធានដែលចាំបាច់ដើម្បីឱ្យខ្លួនអាចបំពេញមុខងារឱ្យបានត្រឹមត្រូវ*” ហើយនៅពេលដែលចៅក្រមយល់ឃើញថា ភាពតឹង

[83]ដូចជើងទំព័រខាងលើ មាត្រា ១១។

[84]ដូចជើងទំព័រខាងលើ មាត្រា ៧។

[85]*សន្និសីទរបស់ប្រធានតុលាការកំពូល និងធនធានអាស៊ីប៉ាស៊ីហ្វិក* វិទ្យាស្ថានព័ត៌មានច្បាប់អាស៊ី http://www.asianlii.org/asia/other/CCJAPRes/1995/1.html (ចូលមើលនៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៧)។

[86]ដូចជើងទំព័រខាងលើ។

[87]សេចក្តីថ្លែងការណ៍ទីក្រុងប៉េងកាំងស្តីពីគោលការណ៍នៃឯករាជ្យភាពរបស់តុលាការនៃសមាគម LAWASIA ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៤ http://www.asianlii.org/asia/other/CCJAPRes/1995/1.html (ចូលមើលនៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៧)។



E.C.C.C * CO-INVESTIGATING

01467523



តែងផ្នែកសេដ្ឋកិច្ចធ្វើឲ្យមានការលំបាកបំពេញមុខងាររបស់ខ្លួន នោះប្រព័ន្ធតុលាការ និងតុលាការគួរទទួលបានអាទិភាពកម្រិតខ្ពស់ពីការបែងចែងធនធាន[88]។

៦១. នៅឆ្នាំ ២០០១ នៅក្រោមក្របខណ្ឌនៃកម្មវិធីសកលប្រឆាំងអំពើពុករលួយរបស់ អ.ស.ប និងដោយស្របតាមមហាសន្និបាត អ.ស.ប លើកទី ១០ ស្ដីពីការបង្ការឧក្រិដ្ឋកម្ម និងការប្រព្រឹត្តិមកលើជនល្មើស ក្រុមការងារតុលាការ ដោយមានសមាសភាពជាប្រធានតុលាការកំពូល និងចៅក្រមជាន់ខ្ពស់ផ្សេងទៀតមកពីប្រទេសអាស៊ី និងអាហ្វ្រិក បានរៀបចំសេចក្ដីព្រាងក្រមសីលធម៌របស់តុលាការ គឺគោលការណ៍ទីក្រុង Bangalore ស្ដីពីក្រមសីលធម៌របស់តុលាការ ("គោលការណ៍ទីក្រុង Bangalore")[89]។ គោលការណ៍ទីក្រុង Bangalore ក៏សង្កត់ធ្ងន់ថា *"ឯករាជ្យភាពរបស់តុលាការគឺជាបុរេលក្ខខណ្ឌសម្រាប់នីតិរដ្ឋ និងការធានាជាសារវ័ន្តឱ្យមានការជំនុំជម្រះក្ដីដោយយុត្តិធម៌"*[90] ហេតុនេះ *"វិធានការដ៏មានប្រសិទ្ធភាពត្រូវអនុម័តដោយប្រព័ន្ធតុលាការជាតិដើម្បីផ្ដល់យន្តការអនុវត្តគោលការណ៍ទាំងនេះ ប្រសិនបើវិធានការបែបនេះមិនទាន់មាននៅក្នុងយុត្តាធិការរបស់ខ្លួនទេ"*[91]។

៦២. នៅឆ្នាំ ២០០៧ គណៈកម្មាធិការសិទ្ធិមនុស្ស បានកត់សម្គាល់នៅក្នុងមតិយោបល់ទូទៅថា រដ្ឋនានាមានកាតព្វកិច្ចត្រូវចាត់វិធានការជាក់លាក់ដើម្បីធានាឯករាជ្យភាពរបស់តុលាការ ដោយការពារចៅក្រម ពីការជ្រៀតជ្រែកផ្នែកនយោបាយក្នុងរូបភាពណាមួយនៅក្នុងការធ្វើសេចក្ដីសម្រេចរបស់តុលាការ ដោយបង្កើត ឬអនុម័តច្បាប់ដែលចែងជាអាទិ៍អំពីប្រាក់បៀវត្សរបស់តុលាការ[92]។

[88]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤១-៤២។

[89]*របាយការណ៍កិច្ចប្រជុំលើកទី ២ របស់ក្រុមតុលាការស្ដីពីការពង្រឹងសុចរិតភាពរបស់តុលាការ* ថ្ងៃទី ២៤-២៦ ខែ កុម្ភៈ ឆ្នាំ ២០០១ https://www.unodc.org/pdf/crime/gpacpublications/cicp5.pdf (ចូលមើលនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧)។

[90]គោលការណ៍ទីក្រុង Bangalore ស្ដីពីក្រមសីលធម៌របស់តុលាការ ឆ្នាំ ២០០២ ទំព័រ ១ [ភាសាអង់គ្លេស] http://www.unodc.org/pdf/crime/corruption/judicial_group/Bangalore_principles.pdf (ចូលមើលនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៧)។

[91]ដូចជើងទំព័រខាងលើ ទំព័រ ៧ [ភាសាអង់គ្លេស]។

[92]គណៈកម្មាធិការសិទ្ធិមនុស្ស *មតិយោបល់ទូទៅលេខ ៣២* ឆ្នាំ ២០០៧។

៦៣. បទដ្ឋានអន្តរជាតិខាងលើ មានចែងតាមកម្រិតផ្សេងៗគ្នានៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនីមួយៗ ដែលនេះបង្ហាញពីសារៈសំខាន់ជាសារវ័ន្តនៃការរក្សាឯករាជ្យភាពរបស់តុលាការតាមរយៈការធានាថវិកាពីរដ្ឋាភិបាល។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញរបស់ប្រទេសអ៊ុយក្រែន ចែងថា "*រដ្ឋត្រូវធានាឱ្យមានថវិកា និងលក្ខខណ្ឌត្រឹមត្រូវសម្រាប់ដំណើរការប្រព្រឹត្តទៅរបស់តុលាការ និងសកម្មភាពរបស់ចៅក្រម*" ហើយ "*ការចំណាយសម្រាប់ថែរក្សាតុលាការត្រូវបែងចែកដាច់ដោយឡែកពីថវិការដ្ឋរបស់អ៊ុយក្រែន*"[93]។

៦៤. ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប ក៏បានលើកឡើងផងដែរនៅចំពោះមុខក្រុមប្រឹក្សាអឺរ៉ុប អំពីភាពពាក់ព័ន្ធនៃបទដ្ឋានទាំងនេះនៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ។ ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប បានសិក្សាលើករណីមួយចំនួនដែលបានកើតឡើងនៅក្នុងប្រព័ន្ធតុលាការរបស់រដ្ឋសមាជិកនៅអឺរ៉ុប ដែលការសិក្សានេះបានបង្ហាញពីហានិភ័យមានជាប់ស្រាប់ដោយសារកង្វះថវិការ៉ាំរ៉ៃ ដូចជា ការកាត់បន្ថយបុគ្គលិកដែលកាត់បន្ថយសមត្ថភាពរបស់តុលាការក្នុងការសម្រេចរឿងក្តីឱ្យបានក្នុងពេលវេលាមួយសមស្រប ហើយមានគុណភាពដែលត្រូវការជាចាំបាច់ ហើយក៏ប៉ះពាល់ដល់ការគោរពរបស់សាធារណជនចំពោះតុលាការផងដែរ។ ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប បានធ្វើការសន្និដ្ឋានថា "*កង្វះថវិការ៉ាំរ៉ៃគួរត្រូវសង្គមទាំងមូលចាត់ទុកថាមិនអាចទទួលយកបានទេ។ វាបំផ្លាញមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យដែលគ្រប់គ្រងដោយនីតិរដ្ឋ*"[94]។

### ii. <u>យុត្តិសាស្ត្រ</u>

៦៥. ច្បាប់ព្រហ្មទណ្ឌ និងយុត្តិសាស្ត្រសិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងទំនាក់ទំនងរវាងឯករាជ្យភាពរបស់តុលាការជាមួយនឹងភារកិច្ចរបស់រដ្ឋាភិបាលក្នុងការធានាផ្តល់ថវិកា បង្ហាញឱ្យឃើញពីសារៈសំខាន់នៃការធានាថវិកាសម្រាប់ អ.វ.ត.ក ដើម្បីរារាំងបញ្ហាហិរញ្ញវត្ថុកុំឱ្យមានឥទ្ធិពលមកលើកិច្ចដំណើរការនីតិវិធី ហេតុនេះធានាឱ្យមានឯករាជ្យភាពរបស់តុលាការ។

---

[93] រដ្ឋធម្មនុញ្ញរបស់ប្រទេសអ៊ុយក្រែន ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៦ មាត្រា ១៣០។

[94] ក្រុមប្រឹក្សាយោបល់ចៅក្រមអឺរ៉ុប *បញ្ហាប្រឈមសម្រាប់ឯករាជ្យភាព និងភាពឥតលម្អៀងរបស់តុលាការនៅរដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២៤ អាចរកបានទៅគេហទំព័រ៖ http://www.coe.int/t/DGHL/cooperation/ccje/textes/SGInf(2016)3rev%20Challenges%20for%20judicial%20independence%20and%20impartiality.asp#P19_102 ចូលមើលចុងក្រោយនៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៧។

៦៦. តុលាការSCSL ស្រដៀងនឹងអ.វ.ត.ក ដែរ បានបង្កើតឡើងតាមរយៈសន្ធិសញ្ញារវាង អ.ស.ប ជាមួយនឹងរដ្ឋាភិបាលសេរ៉ាឡេអូន("កិច្ចព្រមព្រៀង SCSL")។ ប៉ុន្តែ ខុសពី អ.វ.ត.ក កិច្ចព្រមព្រៀង SCSL ចែងយ៉ាងច្បាស់ថា "*ការចំណាយរបស់តុលាការពិសេសនេះត្រូវជាបន្ទុកថវិកាស្ម័គ្រចិត្តចូលរួមចំណែកពីសហគមន៍អន្តរជាតិ*"[95]។

៦៧. ខចែងនេះត្រូវបានចោទសួរនៅក្នុងសំណុំរឿង *រដ្ឋអាជ្ញាតទល់នឹង* *Sam Hinga Norman* ដែលជនជាប់ចោទបានដាក់ញត្តិតវ៉ាអំពីឯករាជ្យភាពរបស់ចៅក្រមតុលាការ SCSL ដោយផ្អែកលើមូលដ្ឋានថា តុលាការនេះទទួលរងឥទ្ធិពលពីប្រព័ន្ធផ្តល់ជំនួយដោយស្ម័គ្រចិត្ត[96]។ គួរកត់សម្គាល់ថា ក៏មានខចែងផ្សេងទៀតច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀង SCSL ដែលធ្វើឱ្យកិច្ចព្រមព្រៀងនេះខុសពីកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា[97]។ ករណីនេះមិនដូចគ្នាតែម្តងទេ ជាមួយនឹងបញ្ហាចោទអំពីឯករាជ្យភាពរបស់តុលាការដោយសារកង្វះថវិកា ដែលជាបញ្ហាចោទត្រូវពិចារណានៅក្នុងសំណើនេះ ប៉ុន្តែ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅ SCSL លើប្រធានបទទូទៅជាងនេះអំពីឯករាជ្យភាពរបស់តុលាការ គឺមានលក្ខណៈពាក់ព័ន្ធគ្នា។

៦៨. ឧទាហរណ៍ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅ SCSL បានបញ្ជាក់ថា "*មានការទទួលស្គាល់ជាយូរមកហើយថា ឯករាជ្យភាពរបស់តុលាការស្ថិតនៅលើសរសរស្តម្ភគ្រោះពីរ គឺសុវត្ថិភាពអាណត្តិការងាររបស់ចៅក្រម និងការធានាប្រាក់បៀវត្សរបស់តុលាការ ព្រមទាំងការពារ*

[95] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរដ្ឋាភិបាលសេរ៉ាឡេអូនស្តីពីការបង្កើតតុលាការពិសេសសម្រាប់សេរ៉ាឡេអូន មាត្រា ៦។

[96] រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Sam Hinga Norman* សេចក្តីសម្រេចលើញត្តិបឋមដោយផ្អែកលើមូលដ្ឋានថាខ្វះយុត្តាធិការ (ឯករាជ្យភាពរបស់តុលាការ) អង្គជំនុំជម្រះតុលាការកំពូលរបស់ SCSL (SCSL-2004-14-AR72(E) ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ៣០។

[97] ឧទាហរណ៍ មាត្រា ២៣ នៃកិច្ចព្រមព្រៀងនោះ ចែងថា តុលាការអាចត្រូវបញ្ឈប់បានតែពេលបានបញ្ចប់សកម្មភាពតុលាការរបស់ SCSL តែប៉ុណ្ណោះ ហើយមាត្រា ៦ ចែងថា ប្រសិនបើមិនមានថវិកាស្ម័គ្រចិត្តគ្រប់គ្រាន់ អគ្គលេខាធិការត្រូវស្វែងរកមធ្យោបាយផ្សេងដើម្បីផ្តល់ហិរញ្ញវត្ថុដល់តុលាការនេះ។



CO-INVESTIGATING *ECCC*

*ឯករាជ្យភាពរបស់តុលាការពីការផ្លាស់ប្តូរតាមការនឹកឃើញ និងការផ្លាស់ប្តូរចិត្តភ្លាមៗរបស់រដ្ឋាភិបាល ឬស្ថាប័នដែលមានបន្ទុកទទួលខុសត្រូវផ្តល់ថវិកាដល់តុលាការ*' [98]។

៦៩. ជាពិសេស ចៅក្រម Geoffrey Robertson បានបញ្ជាក់នៅក្នុងមតិយោបល់ដាច់ដោយឡែករបស់គាត់ថា "*វានឹង [...]ក្លាយជាអំពើមិនទទួលខុសត្រូវផ្នែកសីលធម៌ ប្រសិនបើសហគមន៍អន្តរជាតិបង្កើតប្រព័ន្ធតុលាការព្រហ្មទណ្ឌ ជាពិសេសពាក់ព័ន្ធនឹងការបាត់បង់សេរីភាពដោយសារការចាប់ខ្លួន និង ការឃុំខ្លួន ហើយអាចឈានដល់កាត់ទោសឱ្យជាប់ឃុំខ្លួនផងដែរ តែប្រព័ន្ធតុលាការនេះខ្វះការធានាថវិកា ដែលចាំបាច់ដើម្បីបញ្ចប់ភារកិច្ចរបស់ខ្លួន*"[99]។ គាត់បានបន្តអង្កេតថា ថវិកាសម្រាប់តុលាការទាំងមូល មិនមែនសម្រាប់តែចៅក្រមប៉ុណ្ណោះទេ គួររៀបចំចាត់ចែងឡើងដើម្បីធានាថា សិទ្ធិការពារក្តីជាសារវ័ន្តត្រូវបានគោរព ហើយមិនមានគ្រឿងលើកទឹកចិត្តឱ្យចៅក្រមសម្រេចលើរឿងក្តីណាមួយតាមរបៀបណាមួយនោះឡើយ[100]។

៧០. ការចំណាយរបស់តុលាការ ICTY និង ICTR មានការធានាជាង ដោយពិនិត្យឃើញថាការចំណាយនេះត្រូវចាត់ទុកយ៉ាងច្បាស់ថាជាការចំណាយរបស់ អ.ស.ប ហេតុនេះទទួលបានថវិកាជាចម្បងពីចំណែកថវិកាត្រូវបង់ពីរដ្ឋសមាជិក[101]។ ប៉ុន្តែ សាលាក្តីទាំងនេះក៏ទទួលយកថវិកាស្ម័គ្រចិត្តផងដែរ[102]។

៧១. តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR") បានធ្វើសេចក្តីសម្រេចស្រដៀងនឹងអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ SCSL ដែរ។ នៅក្នុងរឿងក្តី *Salov តទល់នឹងអ៊ុយក្រែន* (ដកស្រង់

---

[98]រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Sam Hinga Norman* សេចក្តីសម្រេចលើញត្តិបឋមដោយផ្អែកលើមូលដ្ឋានថាខ្វះយុត្តាធិការ (ឯករាជ្យភាពរបស់តុលាការ) អង្គជំនុំជម្រះតុលាការកំពូលរបស់ SCSL (SCSL-2004-14-AR72(E) ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ២៦។

[99]រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Sam Hinga Norman* សេចក្តីសម្រេចលើញត្តិបឋមដោយផ្អែកលើមូលដ្ឋានថាខ្វះយុត្តាធិការ (ឯករាជ្យភាពរបស់តុលាការ) អង្គជំនុំជម្រះតុលាការកំពូលរបស់ SCSL (SCSL-2004-14-AR72(E) ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ មតិយោបល់ដាច់ដោយឡែករបស់ចៅក្រម Geoffrey Robertson កថាខណ្ឌ ២២។

[100]ដូចដើងទំព័រខាងលើ កថាខណ្ឌ ២២-២៣។

[101]ថវិកាត្រូវបង់ (assessed contributions) គឺជាថវិការបស់រដ្ឋសមាជិកនីមួយៗ ដែលត្រូវបង់សម្រាប់ចំណាយរបស់អង្គការសហប្រជាជាតិ។

[102] William A. Schabas *សាលាក្តីព្រហ្មទណ្ឌអន្តរជាតិអង្គការសហប្រជាជាតិ៖ អតីតយូហ្គោស្លាវី រវ៉ាន់ដា និងសេរ៉ាឡេអូន* ឆ្នាំ ២០០៦ Cambridge University Press ញូយ៉ក ទំព័រ ៦២២-៦២៣ [ភាសាអង់គ្លេស]។

ដោយអង្គជំនុំជម្រះតុលាការកំពូលរបស់ អ.វ.ត.ក) តុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចថា ដោយផ្អែកលើមូលដ្ឋានថាមិនមានការធានាផ្នែកច្បាប់ និងហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ដើម្បីប្រឆាំងនឹងសម្ពាធពីខាងក្រៅមកលើចៅក្រមដែលជំនុំជម្រះរឿងក្តី ទើបមន្ទិលសង្ស័យរបស់អ្នកដាក់ពាក្យសុំទាក់ទងនឹងភាពឥតលម្អៀងរបស់ចៅក្រម អាចមានយុត្តិកម្មសត្យានុម័ត[103]។

៧២. ដូចដែលអ្នកសិក្សាមួយចំនួនបានបញ្ចេញមតិយោបល់ដែរ ថវិកាដែលពឹងផ្អែកតែលើការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្ត ធ្វើឲ្យតុលាការ និងសាលាក្តី ងាយទទួលរងឥទ្ធិពល និងការកែកុនមិនសមស្រប ដែលមិនស្របតាមឯករាជ្យភាពរបស់តុលាការ។ ពលរដ្ឋក៏ត្រូវតែមានប្រព័ន្ធតុលាការមួយដែលមានធនធានគ្រប់គ្រាន់ដើម្បីចាត់ចែងកិច្ចការរដ្ឋបាលតុលាការឲ្យមានប្រសិទ្ធផល និងមានសណ្តាប់ធ្នាប់[104]។ ដូចចៅក្រម Schabas បានបញ្ជាក់ដែរ *"ទាំងរដ្ឋអាជ្ញា ទាំងចៅក្រម មិនគួរបង្ខំចិត្តត្រូវពិចារណាលើផលលំបាកសម្រាប់សាលាក្តី ក្នុងករណីដែលរដ្ឋអាជ្ញា និងចៅក្រមបន្តកិច្ចស៊ើបសួរ និងចេញដីកាបញ្ជូនទៅជំនុំជម្រះណាដែលប៉ះពាល់ដល់ប្រយោជន៍របស់រដ្ឋណាមួយ ដែលជាម្ចាស់ជំនួយដ៏សំខាន់ ទោះបីជាការប៉ះពាល់ដោយប្រយោលក៏ដោយ"*[105]។

៧៣. យើងសូមគូសបញ្ជាក់ថា យើងដកស្រង់ការលើកយោងទាំងនេះ មិនមែនដោយសារព្រួយបារម្ភអំពីប្រាក់បៀវត្សផ្ទាល់ខ្លួនរបស់យើងឡើយ ពីព្រោះថា យើងទាំងពីរបានកសាងអាជីពការងារជោគជ័យរួចទៅហើយនៅក្រៅ អ.វ.ត.ក ដែលយើងអាចត្រឡប់ទៅវិញភ្លាមៗ ប្រសិនបើ អ.វ.ត.ក បរាជ័យ ឬនៅពេលដែលអាណត្តិរបស់យើង តាមមាត្រា ៥ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបញ្ចប់ដោយការបំពេញភារកិច្ចរបស់យើង។ ហើយនេះក៏មិនមែនជាបញ្ហាសម្រាប់បុគ្គលិកដ៏ច្រើននាក់របស់យើងដែល

---

[103]តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Salov តទល់នឹងអ៊ុយក្រែន* ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០៥ កថាខណ្ឌ ៨៦។

[104]William A. Schabas *សាលាក្តីព្រហ្មទណ្ឌអន្តរជាតិអង្គការសហប្រជាជាតិ៖ អតីតយូហ្គោស្លាវី រ៉ាវ៉ាន់ដា និង សេរ៉ាឡេអូន* ឆ្នាំ ២០០៦ Cambridge University Press ញូយ៉ក ទំព័រ ៦២៣ [ភាសាអង់គ្លេស]។ Jeffrey Jackson *"ឯករាជ្យភាពរបស់តុលាការ ថវិកាគ្រប់គ្រាន់សម្រាប់តុលាការ និងអំណាចមានជាប់ស្រាប់របស់តុលាការ"* ទស្សនាវដ្តីច្បាប់ឈ្មោះ *Maryland Law Review* ឆ្នាំទី ៥២ (ឆ្នាំ ១៩៩៣) ទំព័រ ២១៨ [ភាសាអង់គ្លេស]។

[105]William A. Schabas *សាលាក្តីព្រហ្មទណ្ឌអន្តរជាតិអង្គការសហប្រជាជាតិ៖ អតីតយូហ្គោស្លាវី រ៉ាវ៉ាន់ដា និង សេរ៉ាឡេអូន* ឆ្នាំ ២០០៦ Cambridge University Press ញូយ៉ក ទំព័រ ៦២៣ [ភាសាអង់គ្លេស]។

មានវិជ្ជាជីវៈខ្ពស់ និងមានភក្ដីភាព ព្រមទាំងផ្នែកផ្សេងទៀតនៅ អ.វ.ត.ក ដែលនឹងត្រូវស្វែងរកការងារថ្មី៖ ឧទាហរណ៍ មិនមានការភ្ញាក់ផ្អើលអ្វីទេ នៅពេលដែលវិបត្តិថវិកានាពេលបច្ចុប្បន្ននេះបានធ្វើឱ្យបុគ្គលិក ជាពិសេសបុគ្គលិកអន្តរជាតិ ស្វះស្វែងរកកន្លែងការងារថ្មីយ៉ាងសកម្ម។ មិនចាំបាច់ពន្យល់ទេថា ហេតុអ្វីបានជាការកាត់បន្ថយបុគ្គលិក អាចនាំឱ្យបាត់បង់យ៉ាងច្រើននូវអ្នកមានបទពិសោធន៍ការងារក្នុងស្ថាប័ន ហើយមានតែធ្វើឱ្យពន្យារពេលថែមទៀតតែប៉ុណ្ណោះ ហេតុនេះធ្វើឱ្យចំណាយកាន់តែកើនឡើង។ បទពិសោធន៍របស់ស្ថាប័នមុនៗដូចជា តុលាការ ICTY និង ICTR គួរតែយកធ្វើជាគំរូដ៏សំខាន់អំពីផលលំបាកដោយសារខ្វះការយកចិត្តទុកដាក់លើបញ្ហាទាំងនេះ។

៧៤. ប៉ុន្តែ កត្តាប្រាក់បៀវត្សគឺជាកត្តាមួយក្នុងចំណោមកត្តាគ្រឹះគាំទ្រទស្សនាទានអំពីឯករាជ្យភាពរបស់ស្ថាប័នតុលាការ ដែលកំពុងស្ថិតនៅក្រោមការគំរាមកំហែងសម្រាប់ អ.វ.ត.ក ដោយសារយន្តការផ្ដល់ថវិកាដែលអនុវត្តដោយ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា។

## IV. សេចក្ដីសន្និដ្ឋាន

៧៥. បញ្ហាប្រឈមផ្នែកថវិកា និងថវិកាមិនគ្រប់គ្រាន់ដែលតុលាការបានប្រឈមមុខនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នៅតែបន្តមានរហូតដល់សព្វថ្ងៃនេះ ហើយជារបាំងឧបសគ្គជាក់ស្ដែងដ៏ធំសម្រាប់បន្តប្រតិបត្តិការរបស់ អ.វ.ត.ក ក៏ដូចជាប្រតិបត្តិការនាពេលអនាគត និងសមត្ថភាពរបស់តុលាការ ដើម្បីបំពេញតាមបទដ្ឋានអន្តរជាតិស្ដីពីឯករាជ្យភាពរបស់តុលាការ ហេតុនេះហើយជារបាំងឧបសគ្គជាក់ស្ដែងដ៏ធំសម្រាប់ការជំនុំជម្រះក្ដីដោយយុត្តិធម៌។ កន្លងមកនេះ ការផ្ដល់ថវិកាបានធ្វើឡើងតាមដំណាក់កាលតាមរយៈការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្ត ជាការពិតមួយដែលធ្វើឱ្យការងារទាំងភាគីជាតិ ទាំងភាគីអន្តរជាតិ ស្ថិតនៅក្នុងសភាពគ្មានស្ថិរភាពជាបន្តបន្ទាប់ ហើយឥឡូវនេះឈានដល់ចំណុចវិបត្តិ។ ដូចដែលបទដ្ឋានជាតិ និងអន្តរជាតិខាងលើ បង្ហាញដែរ អស្ថិរភាពបែបនេះបង្កើតឱ្យមានភាពមិនច្បាស់លាស់មួយកម្រិតសម្រាប់ប្រព័ន្ធតុលាការ ដែលនេះអាចបង្ខំឱ្យចេញលទ្ធផលមួយចំនួនសម្រាប់កិច្ចដំណើរការនីតិវិធី ដែលនឹងរំលោភបំពានបទដ្ឋានអន្តរជាតិស្ដីពីឯករាជ្យភាពរបស់តុលាការ និងកិច្ចការរដ្ឋបាលតុលាការប្រកបដោយប្រសិទ្ធភាព។

៧៦. ភារកិច្ចរបស់យើងគឺត្រូវទប់ស្កាត់ហេតុការណ៍ ដែលនាំឱ្យមានសភាពការណ៍មិនអាចទទួល

យកបានដូចបានរៀបរាប់ខាងលើ។ ពេលវេលាដែលយើងមានដើម្បីចាត់វិធានការទប់ស្កាត់បែបនេះត្រូវកំណត់តាមពេលចុងក្រោយនៃថវិកាដែលធានាថាមាននាពេលបច្ចុប្បន្ននេះ នៅដំណាក់នេះ ពោលគឺនៅត្រឹមចុងខែ មិថុនា ឆ្នាំ ២០១៧។

៧៧. មាត្រា ៣(៣) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ចែងយ៉ាងច្បាស់ ហើយយើងទាំងពីរ ក៏បានស្បថតាមន័យនេះដែរថា *"ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ"*។ នេះរាប់បញ្ចូលទាំងការណែនាំដោយផ្ទាល់ ឬដោយសម្ងាត់តាមរយៈការជូនដំណឹងដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ និងមធ្យោបាយផ្សេងទៀតដែលបង្ហាញដោយប្រយោលថាមានឥទ្ធិពលមកលើកិច្ចដំណើរការនីតិវិធី ដូចជា ការអនុវត្តតាមសូចនាករណ៍សមិទ្ធផលគន្លឹះ ដែលមិនសាកសមជាមួយនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទេ ពោលគឺជាការណែនាំដែលធ្វើឡើងក្នុងគោលបំណងជំរុញឱ្យមានថវិកាថែមទៀត។

៧៨. ជាក់ស្តែង វិធីសាស្ត្របច្ចុប្បន្ននេះរបស់ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសម្ចាស់ជំនួយ ក្នុងការផ្តល់ថវិកាដល់ អ.វ.ត.ក ដូចបានបង្ហាញសម្រាប់ថវិកាឆ្នាំ ២០១៧ អាចស្ថិតនៅក្នុងសេណារីយ៉ូណាមួយក្នុងចំណោមសេណារីយ៉ូទាំងពីរនេះ ហើយ គ្មានសេណារីយ៉ូមួយណាធ្វើជាមូលដ្ឋានគ្រឹះ ដែលអាចទទួលយកបានទេ សម្រាប់ទំនាក់ទំនងរវាងម្ចាស់ថវិកាជាមួយនឹងតុលាការ តាមការយល់ឃើញរបស់យើង៖

ក. ម្ចាស់ថវិកា ដឹងយ៉ាងច្បាស់អំពីបញ្ហា និងការរឹតត្បិតបច្ចុប្បន្ននេះរបស់ អ.វ.ត.ក ដែលបានពន្យល់ដោយផ្នែកផ្សេងៗរបស់តុលាការ ជាពិសេសដោយចៅក្រមនៅក្នុងរបាយការណ៍បច្ចុប្បន្នភាពប្រចាំត្រីមាស ស្តីពីផែនការបញ្ចប់ការងារ និងតាមវិធីផ្សេងៗទៀត ហើយក៏ដឹងច្បាស់អំពីផលប៉ះពាល់ដោយសារការកាត់បន្ថយថវិកាដែរ ប៉ុន្តែ នៅតែសម្រេចផ្តោតតែលើអាទិភាពលើកត្តាថវិកា ហើយកាត់បន្ថយបន្ទុកការចូលរួមចំណែករបស់ខ្លួនចំពោះការចំណាយប្រតិបត្តិការរបស់ អ.វ.ត.ក ដោយស្នើឱ្យតុលាការ សម្រួលប្រតិបត្តិការរបស់ខ្លួនទៅតាមថវិកាដែលមាន។ ម្ចាស់ថវិកា ក៏អាចមិនចំណាយថវិកា ទោះបីពួកគេឯកភាព ផ្អែកលើមូលដ្ឋាននៃការមន្ទិលលើការយល់ឃើញរបស់តុលាការលើបញ្ហាថវិកា។



CO-INVESTIGATING ... E.C.C.C * C.E.T.C

ខ. ម្ចាស់ថវិកា ទោះបីជាមានការពន្យល់ដូចបានលើកឡើងនៅចំណុច (ក) យ៉ាងណាក៏ដោយ ក៏នៅតែមិនយល់ពីបញ្ហាដែលតុលាការកំពុងប្រឈមមុខ និងផលប៉ះពាល់ដោយសារការកាត់បន្ថយថវិកាបន្ថែមទៀត ហើយម្ចាស់ថវិកាខ្វល់តែរឿងកាត់បន្ថយបន្ទុកការចូលរួមចំណែករបស់ខ្លួនចំពោះការចំណាយប្រតិបត្តិការរបស់តុលាការ ដោយស្នើឱ្យតុលាការ សម្រួលប្រតិបត្តិការរបស់ខ្លួនទៅតាមថវិកាដែលមាន។ ម្ចាស់ថវិកា ក៏អាចមិនចំណាយថវិកា ទោះ បីពួកគេឯកភាព ផ្អែកលើមូលដ្ឋាននៃការមន្ទិល លើការយល់ឃើញរបស់តុលាការលើបញ្ហាថវិកា។

៧៩. ហេតុនេះ បច្ចុប្បន្ននេះ ហើយក៏មានការស្នាក់ស្ទើរយ៉ាងខ្លាំងផងដែរ យើងកំពុងពិចារណាចេញដីកាផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ទាំងស្រុងនៅក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ដោយចាប់ផ្ដើមមិនឱ្យហួសពីចុងខែ មិថុនា ឆ្នាំ ២០១៧ ប្រសិនបើយើងមិនទទួលបានព័ត៌មានអាចទុកចិត្តបាន និងច្បាស់លាស់គ្រប់គ្រាន់ថា ស្ថានភាពថវិកានឹងបានប្រសើរយ៉ាងខ្លាំង ព្រមទាំងព័ត៌មានអំពីចក្ខុវិស័យរៀបចំផែនការត្រៀមទុកជាមុនអាចទុកចិត្តបាន និងច្បាស់លាស់គ្រប់គ្រាន់ ដែលអាចផ្ដល់ជូនយើងនូវការធានាជាចាំបាច់ថា៖

ក. យើងនឹងអាចបញ្ចប់អាណត្តិរបស់យើងដោយជោគជ័យ ទាន់ពេលវេលា និងមានប្រសិទ្ធផលរហូតដល់បានចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿងនីមួយៗ ហើយ

ខ. ម្យ៉ាងទៀត វិធានការដ៏មានប្រសិទ្ធភាពនឹងត្រូវអនុវត្តដើម្បីធានាឱ្យមានថវិកាគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យដីកាដំណោះស្រាយនៅពេលដែលមានបណ្ដឹងឧទ្ធរណ៍ ហើយប្រសិនបើមានការជំនុំជម្រះក្ដី ធានាឱ្យមានថវិកាគ្រប់គ្រាន់សម្រាប់កិច្ចដំណើរនីតិវិធីជំនុំជម្រះក្ដី និងបណ្ដឹងសាទុក្ខ។

៨០. យើងជ្រើសរើសប្រើពាក្យ"ផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ទាំងស្រុង" ជាជាងពាក្យ "លើកលែងការចោទប្រកាន់" ពីព្រោះថា ច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ជាពិសេស វិធានផ្ទៃក្នុង៦៧(៣) ប្រើពាក្យ"លើកលែងការចោទប្រកាន់"សម្រាប់សេណារីយ៉ូពីរផ្សេងគ្នា។





ECCC * CETC INVESTIGATING JUDGES

ប៉ុន្តែ ការប្រើប្រាស់ពាក្យផ្សេងគ្នានេះគ្រាន់តែជាបញ្ហាពាក្យពេចន៍តែប៉ុណ្ណោះ។ ដីកាផ្អាកកិច្ចដំណើរការនីតិវិធីបែបនេះនឹងផ្អែកតែលើមូលហេតុតែមួយគត់ គឺមិនមានការធានាថាមានថវិកាគ្រប់គ្រាន់។ ដីកានេះនឹងផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ហើយបិទផ្លូវមិនឱ្យបើកកិច្ចស៊ើបសួរឡើងវិញទេ។ ជាពិសេស ដីកានេះនឹងមិនសម្រេចលើបញ្ហាចោទអំពីយុត្តាធិការបុគ្គល ឬអង្គសេចក្តីនៃឧក្រិដ្ឋកម្មដែលបានចោទឡើយ។ ជនត្រូវចោទទាំងអស់នឹងត្រូវបន្តសន្មតថាគ្មានទោស ហើយសំណុំរឿងនឹងនៅបើកចំហ។

៨១. ដោយសារដីកាសម្រេចបែបនេះមានលក្ខណៈពិសេស និងមានផលប៉ះពាល់ខ្លាំង ទើបដីកាសម្រេចបែបនេះនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ បញ្ចូលទាំងឯកសារនានាទាក់ទងនឹងសំណើនេះ ហើយសម្រាប់ពេលឥឡូវនេះ យើងដាក់សំណើនេះជាឯកសារសម្ងាត់សិន។

៨២. ប៉ុន្តែ យើងនឹងផ្តល់ការអនុញ្ញាតជាពិសេសឱ្យការិយាល័យរដ្ឋបាល បញ្ជូនបន្តជាការសម្ងាត់ផងដែរនូវសំណៅនៃសំណើនេះជូនការិយាល័យពាក់ព័ន្ធនានានៅ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលប្រទេសម្ចាស់ជំនួយពាក់ព័ន្ធនានា និងលោក David Scheffer អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ ក្នុងគោលបំណងដើម្បីពិគ្រោះយោបល់ដើម្បីជូនដំណឹងអំពីការឆ្លើយតបទៅនឹងសំណើនេះ។

**អាស្រ័យហេតុនេះ យើង ៖**

៨៣. **ជូនដំណឹង** ភាគី ក្នុងសំណុំរឿង ០០៣, ០០៤ និង ០០៤/២ ទាំងអស់ និងការិយាល័យរដ្ឋបាលថា យើងយល់ឃើញថា ការចាត់ចែងថវិកាបច្ចុប្បន្ននេះមិនសមស្របតាមការបំពេញអាណត្តិការងារតុលាការរបស់យើង ឱ្យបានត្រឹមត្រូវ តាមលក្ខខណ្ឌតម្រូវសម្រាប់គោលការណ៍គ្រឹះនៃការជំនុំជម្រះក្តី ដោយយុត្តិធម៌ ឯករាជ្យភាពរបស់តុលាការ និងនីតិរដ្ឋទេ។

៨៤. **ជូនដំណឹង** ភាគីទាំងអស់ និងការិយាល័យរដ្ឋបាល ថា យើងកំពុងពិចារណាចេញដីកាផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ទាំងស្រុងនៅក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ដោយចាប់ផ្តើមពីពេលនេះទៅមិនឱ្យហួសពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧ ហើយដីកាផ្អាកកិច្ចដំណើរការនីតិវិធីបែបនេះនឹងដាក់ជាសាធារណៈ ដោយធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញទៅជាសាធារណៈ និងភ្ជាប់ឯកសារពាក់ព័ន្ធទាំងអស់ទាក់ទងនឹងសំណើនេះ។



C.E.T.C * C.C.C * CO-INVESTIGATING JUDGES

៨៥. **អញ្ជើញ** ភាគីទាំងអស់ និងការិយាល័យរដ្ឋបាល ដាក់សេចក្តីអង្កេតលើបញ្ហាខាងលើ មិនឱ្យហួសរយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសំណើនេះ។

៨៦. **អនុញ្ញាតឱ្យ** ការិយាល័យរដ្ឋបាល បញ្ជូនបន្តជាការសម្ងាត់ផងដែរនូវសំណៅនៃសំណើនេះ ជូនការិយាល័យពាក់ព័ន្ធនានានៅ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលប្រទេសម្ចាស់ជំនួយពាក់ព័ន្ធនានា និងលោក David Scheffer អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ។

៨៧. **អញ្ជើញ** ជាពិសេសដល់ ការិយាល័យរដ្ឋបាល ក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសំណើនេះ សុំពន្យល់ឱ្យបានលម្អិតតាមដែលអាចធ្វើទៅបានអំពី៖

ក. ការវិវត្តនៃការពិភាក្សាថវិកា និង គោលនយោបាយពាក់ព័ន្ធនានានៅ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលប្រទេសម្ចាស់ជំនួយពាក់ព័ន្ធនានាសម្រាប់ថវិកាឆ្នាំ ២០១៧។

ខ. ការព្យាករថវិកាសម្រាប់ឆ្នាំ ២០១៧ និងផលប៉ះពាល់មកលើការគ្រប់គ្រងធនធានសម្រាប់ភាគីជាតិ និងភាគីអន្តរជាតិនៅ អ.វ.ត.ក សម្រាប់រយៈពេលនៅសេសសល់ក្នុងឆ្នាំ ២០១៧។

គ. ផែនការ និងគោលនយោបាយថវិការបស់ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលប្រទេសម្ចាស់ជំនួយពាក់ព័ន្ធនានាសម្រាប់ថវិកាឆ្នាំ ២០១៨ និងក្រោយឆ្នាំ ២០១៨ ជាពិសេសសម្រាប់ សេណារីយ៉ូដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ បន្ទាប់មក មានកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍នៅ អ.ប.ជ ការជំនុំជម្រះក្តី និងបណ្តឹងសាទុក្ខទៅ អ.ជ.ត.ក។

ឃ. ការពិភាក្សាគ្នានៅ អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលប្រទេសម្ចាស់ជំនួយពាក់ព័ន្ធនានា អំពីយុទ្ធសាស្ត្របញ្ចប់ការងារ។

៨៨. **ជូនដំណឹង** ភាគីទាំងអស់ និងការិយាល័យរដ្ឋបាល ថា៖

ក. ចំនួនទំព័រសម្រាប់ការដាក់ឯកសារមតិយោបល់នេះបានបង្កើនរហូតដល់ ២៥ ទំព័រជាអតិបរមា។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C

ខ. ឯកសារត្រូវដាក់ជាភាសាអង់គ្លេស និងភាសាខ្មែរក្នុងពេលដំណាលគ្នា។

គ. សំណើសុំអនុញ្ញាតដាក់តែមួយភាសា នឹងមិនអនុញ្ញាតទេ។

ឃ. ចម្លើយតប និងការឆ្លើយតបទៅនឹងឯកសាររបស់ភាគីផ្សេងទៀត និងការិយាល័យរដ្ឋបាល នឹងមិនអនុញ្ញាតទេ។

៨៩. **ណែនាំ** ដល់ក្រឡាបញ្ជី ឱ្យដាក់ច្បាប់ថតចម្លងនៃសំណើនេះក្នុងសំណុំរឿង ០០៣ និង ០០៤។

ភ្នំពេញ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៧

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juges d'instruction

**ចៅក្រម យូ ប៊ុនឡេង** **ចៅក្រម Michael BOHLANDER**